**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា**

ការិយាល័យទំនាក់ទំនងជាមួយ មាតាបិតា ក្រុមគ្រួសារ សហគមន៍
និងការសហការជាមួយក្រុមសាសនា

សហការជាមួយ

ការិយាល័យផ្នែកគាំទ្រសាលាដែលត្រូវការជំនួយបន្ថែម



# ត្រៀមខ្លួនសម្រាប់ការប្រឡង PSSA

## កូនសៀវភៅរបស់មាតាបិតាសម្រាប់ជ័យជំនះរបស់សិស្ស

KHMER

PARENT UNIVERSITY



*មាតាបិតា គឺជាដៃគូរបស់យើង*

**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដាលហ្វ្យ៉ា**

## ត្រៀមខ្លួនសម្រាប់ការប្រឡង

# PSSA

## កូនសៀវភៅរបស់មាតាបិតា សម្រាប់ជោគជ័យរបស់សិស្ស

សៀវភៅនេះបានរៀបចំឡើងដោយ ការិយាល័យទំនាក់ទំនងជាមួយ មាតាបិតា ក្រុមគ្រួសារ សហគមន៍ និងការសហការជាមួយក្រុមសាសនា – ជាការិយាល័យដែលរៀបចំការចាប់ផ្តើមគំនិតដើម្បីឲ្យ មាតាបិតា និងសហគមន៍ ចូលរួមនៅក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។

កម្មវិធី និងការផ្តើមគំនិតខ្លះ ដែលបានឧបត្ថម្ភដោយ ការិយាល័យរបស់យើងខ្ញុំ មាន៖

- សាកលវិទ្យាល័យមាតាបិតា (ដើម្បីព័ត៌មានបន្ថែម សូមមើលនៅលើក្របខាងក្រោយ)
- មជ្ឈមណ្ឌលព័ត៌មានសម្រាប់មាតាបិតា និងក្រុមគ្រួសារ
- មាតាបិតាជាដៃគូដែលមានសិទ្ធិស្មើគ្នា (ឬ PREP)
- ច្បាប់ Title I ក្រុមប្រឹក្សាមាតាបិតា

ការិយាល័យរបស់យើងខ្ញុំក៏៖

- គាំទ្រដល់កិច្ចការរបស់ អ្នកជួយធ្វើទំនាក់ទំនងនៅសាលាដែលត្រូវការកែលម្អ និងអ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា
- ផ្តល់ជំនួយផ្នែកបច្ចេកទេស និងការហ្វឹកហ្វឺនដល់ក្រុមប្រឹក្សាសាលា
- សហការជាមួយ ក្រុមមាតាបិតា អង្គការ និងក្រុមសាសនា ក្នុងសហគមន៍
- ធ្វើឲ្យមានការចូលរួមពី មាតាបិតា និងសហគមន៍ទូទាំងក្រសួង
- ផ្តល់កម្មវិធីដែលមានគោលដៅច្បាស់លាស់ និងជួយក្រុមគ្រួសារដែលនិយាយភាសាចម្រុះ

ដើម្បីជ្រាបបន្ថែមទៀតអំពីកម្មវិធី និងការបម្រើដែលយើងខ្ញុំផ្តល់ជូន សូមទូរស័ព្ទមកយើងខ្ញុំ លេខ ២១៥.៤០០.៤១៨០ ឬ មកកាន់ មជ្ឈមណ្ឌលព័ត៌មានសម្រាប់មាតាបិតា និងក្រុមគ្រួសាររបស់យើង នៅ 440 N. Broad St., Philadelphia, PA 19130។

បើមើលតាមអ៊ិនធ័រណិត សូមមើលវ៉ិបសៃរបស់ក្រសួង៖ www.philasd.org ហើយចុចត្រង់ពាក្យ "Parent Engagement" បណ្តាញតភ្ជាប់នៅក្នុងប្រអប់ពណ៌បៃតងមានចំណងជើងថា "PARENTS"។

ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា ការចូលរួមរបស់មាតាបិតាមានឥទ្ធិពល ពិតប្រាកដ និងជាក់ស្តែង លើជោគជ័យរបស់សិស្ស។ ពេលដែលមាតាបិតាចូលរួមក្នុងការអប់រំកូន ក្មេងបានពិន្ទុកាន់តែល្អ ទៅរៀនកាន់តែច្រើន បញ្ចប់ការសិក្សាកាន់តែច្រើន ហើយភាគច្រើនទៅរៀនបន្ត មហាវិទ្យាល័យ។ អង្គការ Education World ផ្តល់យោបល់ដូចតទៅ អំពីវិធីដែលមាតាបិតាអាចជួយកូនឲ្យទទួលជោគជ័យ៖

- និយាយជាមួយកូនរាល់ថ្ងៃអំពី សកម្មភាព និងបទពិសោធន៍ នៅសាលា។
- រក្សាការទាក់ទងជាមួយគ្រូរបស់កូនលោកអ្នក ទោះជាគ្មានបញ្ហាអ្វីកើតឡើងក៏ដោយ។
- បង្កើនការយល់ដឹងរបស់កូននូវអ្វីៗដែលនៅជុំវិញខ្លួន ដោយការទៅលេងនៅ ទីផ្សារទំនើបៗ (malls) សារមន្ទីរ សួនសាធារណៈ សួនសត្វ សាកលវិទ្យាល័យ ពហុកីឡាដ្ឋាន រោងកុន/ល្ខោន កសិដ្ឋាន និង កន្លែងសំខាន់ៗ (landmarks) ក្នុងតំបន់។ ត្រូវតែពិភាក្សាគ្នានូវអ្វីៗដែលលោកអ្នកបានឃើញ នៅក្នុងដំណើរកំសាន្ត។
- ធ្វើឲ្យការសិក្សាមានការទាក់ទងគ្នា៖ ជំរុញកូនឲ្យរាប់លុយ សរសេរបញ្ជីទិញរបស់របរ គិតតម្លៃ ថ្លៃលក់ និងពន្ធដា អានបញ្ជីមុខម្ហូប និងកាសែត និងសរសេរលិខិត។
- ទុកពេល និងទីកន្លែងមួយ សម្រាប់ធ្វើកិច្ចការដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះ។
- អានឲ្យកូនស្តាប់រាល់ថ្ងៃ ហើយជំរុញឲ្យកូនអានដោយខ្លួនឯង។ ទៅបណ្ណាល័យរដ្ឋឲ្យបានញឹកញាប់។
- រៀបចំទិសដៅពិបាកៗ ប៉ុន្តែអាចធ្វើទៅបាន។
- ទៅលេងសាលាឲ្យបានញឹកញាប់ ហើយចូលរួមក្នុងសកម្មភាពរបស់សាលាឲ្យបានច្រើន តាមតែអាចធ្វើទៅបាន។
- ត្រូវស្វែងយល់ពីកម្មវិធីសិក្សា និងតម្រូវការពីចំណេះដឹង និងគោលបំណង របស់កូនលោកអ្នក។
- ត្រូវដឹងថា ទស្សនៈរបស់លោកអ្នកអំពី សាលា និងគ្រូ មានឥទ្ធិពលលើឥរិយាបទរបស់កូនលោកអ្នក។

យើងខ្ញុំក៏ជំរុញឲ្យមាតាបិតាមានការ គាំទ្រ និងជឿជាក់ក្នុងចិត្ត។ បង្រៀន កូនលោកអ្នកពីតម្លៃ នៃការឲ្យតម្លៃលើខ្លួនឯង និងជួយឈឺឆ្អាលដល់អ្នកដទៃ។ ត្រូវមានបំណងខ្ពស់ ហើយជួយកូនលោកអ្នកឲ្យសម្រេចបាននូវគោលបំណងទាំងនោះ។ បើសិនជាមានបញ្ហាអ្វីមួយ ត្រូវផ្លាស់ប្តូរការវាយតម្លៃរបស់លោកអ្នក ហើយត្រូវដោះស្រាយបញ្ហានោះជាមួយគ្នា។ ជួយកូនលោកអ្នកឲ្យចេះមានការតស៊ូស្វិតស្វាញ៖ អាចប្រឈមមុខនឹងបរាជ័យ ហើយការរៀនសូត្រពីបរាជ័យនោះ គឺជាគន្លឹះទៅកាន់ជ័យជំនះ។

ជួយកូនឲ្យយល់ពីភាពខុសគ្នារវាង ការស្តីបន្ទោស និងការទទួលខុសត្រូវ។ ការស្តីបន្ទោស ធ្វើឲ្យយើងក្រឡេកមើលអតីតកាល ដោយគ្មានកម្លាំងអាចផ្លាស់ប្តូរអ្វីបាន។ វាធ្វើឲ្យមានការអន់ខ្សោយដល់ ការចង់ដឹងចង់យល់ និងការឲ្យតម្លៃលើខ្លួនឯង របស់យើង។ ការទទួលខុសត្រូវ បញ្ជាក់ឲ្យឃើញពីភាពជាម្ចាស់ នៃលទ្ធផល – វាជាការសំឡឹងទៅមុខ ហើយជាការបង្កើតនូវគំនិតថ្មី និងការឲ្យតម្លៃលើខ្លួនឯង។ កុំស្តីបន្ទោស ត្រូវជំរុញកូនលោកអ្នកឲ្យចេះទទួលខុសត្រូវ ចំពោះអំពើ ដែលគេបានធ្វើ។

## ប្រតិទិនសម្រាប់ការប្រឡង PSSA ឆ្នាំ ២០១១-២០១២

| ការវាយតម្លៃ | ថ្ងៃខែ | ថ្នាក់ទី |
|---|---|---|
| ការប្រឡង PSSA ឡើងវិញ សម្រាប់សិស្ស ថ្នាក់ទី១២ ផ្នែក គណិតវិទ្យា ការអាន ចំណេះវិទ្យាសាស្ត្រ និង ការសរសេរ | ថ្ងៃទី២៤ តុលា ដល់ ទី៤ វិច្ឆិកា ២០១១ | ១២ |
| ការប្រឡង PSSA ផ្នែក គណិតវិទ្យា និងការអាន<br>PSSA–M គណិតវិទ្យា<br>PSSA–M ការអាន | ថ្ងៃទី១២ ដល់ ទី២៣ ខែមីនា ២០១២ | ៣ ដល់ ៨ ១១<br>៤ ដល់ ៨ ១១<br>៤ ដល់ ៨ ១១ |
| ប្រឡង គណិតវិទ្យា និងការអាន សម្រាប់សិស្សដែលមិនបានប្រឡង | ថ្ងៃទី២៦ ដល់ ទី៣០ ខែមីនា ២០១២ | ធ្វើតាមត្រូវការ |
| PSSA ការសរសេរ | ថ្ងៃទី១៦ ដល់ ទី២០ ខែមេសា ២០១២ | ៥ ៨ ១១ |
| PSSA ចំណេះវិទ្យាសាស្ត្រ<br>PSSA–M ចំណេះវិទ្យាសាស្ត្រ | ថ្ងៃទី២៣ ដល់ ទី២៧ ខែមេសា ២០១២ | ៤ ៨ ១១<br>៨ ១១ |
| ប្រឡង សរសេរ និងចំណេះវិទ្យាសាស្ត្រ សម្រាប់សិស្សដែលមិនបានប្រឡង | ទី៣០ ខែមេសា ដល់ ទី៤ ខែឧសភា ២០១២ | ធ្វើតាមត្រូវការ |
| PASA គណិតវិទ្យា និង ការអាន | ថ្ងៃទី១៣ ខែកុម្ភៈ ដល់ ទី២៣ ខែមីនា ២០១២ | ៣ ដល់ ៨ ១១ |
| PASA ចំណេះវិទ្យាសាស្ត្រ | ថ្ងៃទី១ ដល់ ២៥ ខែឧសភា ២០១២ | ៤ ៨ ១១ |
| ការប្រឡង ACCESS សម្រាប់សិស្ស ELLs | ថ្ងៃទី២៣ ខែមករា ដល់ ទី២ ខែមីនា ២០១២ | មត្តេយ្យ ដល់ ១២ |

**ជាការសំខាន់ណាស់ដែលសិស្សមកសាលាតាមថ្ងៃខែដែលគេបានចាត់ឲ្យសម្រាប់ការប្រឡងPSSA។** សូមធ្វើយ៉ាងណាឲ្យកូនមកសាលា ទាន់ពេល សម្រាកឲ្យបានគ្រប់គ្រាន់ និងត្រៀមខ្លួនជាស្រេច សម្រាប់ប្រឡង រាល់ថ្ងៃប្រឡងទាំងអស់។

## ប្រភេទនៃកម្រិតអប់រំសម្រាប់ប្រព័ន្ធវាយតម្លៃសាលារបស់រដ្ឋផិនស៊ីលវេញ៉ា

ខាងក្រោមនេះគឺជាការពណ៌នាពីប្រភេទនៃកម្រិតអប់រំទូទៅ។ កម្រិតថ្នាក់ និងមុខវិជ្ជានីមួយៗ មានការពណ៌នាច្បាស់លាស់ ដែលអាចឃើញនៅក្នុងវិបសៃរបស់ ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា *http://www.education.state.pa.us* (ពីបញ្ជីនៅខាងឆ្វេងដៃ រើសយកពាក្យ "Programs", "O ដល់ R", "Pennsylvania System of School Assessment", "Items and Scoring Samples")។

- **ក្រោមកម្រិត/Below Basic** - មិនសូវចេះបកស្រាយបំភ្លឺបានតាមកម្រិតថ្នាក់នូវ គំនិត/ការប៉ិនប្រសប់ សម្រាប់មុខវិទ្យា/កិច្ចការ ដែលដាក់ឲ្យធ្វើណាមួយ។
- **ស្មើកម្រិត/Basic** - ពេលខ្លះចេះបកស្រាយបំភ្លឺបានតាមកម្រិតថ្នាក់នូវ គំនិត/ការប៉ិនប្រសប់ សម្រាប់មុខវិទ្យា/កិច្ចការ ដែលដាក់ឲ្យធ្វើណាមួយ។
- **ស្ទាត់ជំនាញ/Proficient** - ភាគច្រើនចេះបកស្រាយបំភ្លឺបានតាមកម្រិតថ្នាក់នូវ គំនិត/ការប៉ិនប្រសប់ សម្រាប់មុខវិទ្យា/កិច្ចការ ដែលដាក់ឲ្យធ្វើណាមួយ។
- **កម្រិតខ្ពស់/Advanced** - ចេះបកស្រាយបំភ្លឺនូវការយល់ដឹងបានជ្រៅជ្រះតាមកម្រិតថ្នាក់គ្រប់ពេលវេលានូវ គំនិត/ការប៉ិនប្រសប់ ហើយប្រើវិធីសាស្ត្រដែលគិតវែងឆ្ងាយដើម្បីដោះស្រាយកិច្ចការដាក់ឲ្យធ្វើ។

## គន្លឹះដែលមានប្រយោជន៍សម្រាប់មាតាបិតា៖ វិធីជួយកូនបង្កើនចំណេះសម្រាប់ការប្រឡង PSSA

**មធ្យោបាយដែលសំខាន់បំផុតដើម្បីជួយបង្កើនការសិក្សារបស់កូនគឺ ផ្តល់នូវការគាំទ្រ និងបង្ហាញនូវទស្សនៈល្អៗអំពី វិធីប្រឡង និងសាលា ជាទូទៅ។** ទស្សនៈមិនល្អ ជូនកាលអាចផ្ទេរទៅក្មេង ហើយអាចមានឥទ្ធិពលលើសេចក្តីសម្រេចនៃការសិក្សាដោយអចេតនា។

មានមធ្យោបាយជាច្រើនដែលលោកអ្នកអាចជួយកូនឲ្យធ្វើបានល្អ លើការប្រឡងតាមខ្នាតគំរូ។ សូមចាំថា ការត្រៀមខ្លួនសម្រាប់ការប្រឡង គឺជាសកម្មភាពដែលត្រូវធ្វើយូរ និងធ្វើជាបន្ត ដែលអាចយកធ្វើជាសកម្មភាពប្រចាំថ្ងៃក្នុងជីវិត។

សកម្មភាពប្រចាំថ្ងៃដើម្បីជួយត្រៀមកូនរបស់លោកអ្នកសម្រាប់ការប្រឡង៖

- ពិភាក្សាពីករណីយកិច្ចនៃការសិក្សារបស់កូន ជាមួយពួកគេ – **សួរកូនថា "តើឯងរៀនបានដូចម្តេចដែរនៅសាលា?"**
- **ជំរុញឲ្យកូនសួរសំណួរអំពីអ្វីៗដែលពួកគេមិនយល់** – គ្មានអ្វីដែលត្រូវគិតថាជាសំណួរល្ងង់ខ្លៅទេ!
- **បង្ហាញចំណាប់អារម្មណ៍លើ កិច្ចការសាលា និងលំហាត់របស់កូន** ពិនិត្យមើលឲ្យដឹងថាកិច្ចការទាំងនោះបានធ្វើចប់រួចរាល់។ លំហាត់អាចជាសញ្ញា ឲ្យដឹងថាកូនមានភាពអន់ខ្សោយ ហើយជាពេលដែលត្រូវពង្រឹងចំណុចអន់ខ្សោយទាំងនេះ។
- **ផ្តល់ឲ្យកូននៅកន្លែងសិក្សាដែល ស្ងាត់ស្ងៀម និងកក់ក្តៅ។**
- **ទាក់ទងជាមួយគ្រូរបស់កូន។**
- **ជំរុញឲ្យកូនប្តេជ្ញារៀន ឲ្យបានពូកែ និងកំណត់គោលបំណងដែលត្រូវធ្វើ។** គាំទ្រគ្រប់កិច្ចសន្យា។



## គន្លឹះសម្រាប់គណិតវិទ្យា៖

- **ពិភាក្សាពីប្រភេទនៃការងារដែលប្រើជំនាញគណិតវិទ្យា។** ក្មេងតែងតែសួរថា "ហេតុអ្វីបានជាខ្ញុំត្រូវរៀនពិជគណិត?" ជាការសំខាន់ដែលពួកគេត្រូវដឹងថា គណិតវិទ្យាគឺជាមុខវិជ្ជាមួយដែលសំខាន់ក្នុងជីវិតរបស់មនុស្សគ្រប់រូប។ ជាងឈើ និងអ្នកសង់អាគារ ប្រើសមីការគណិតវិទ្យា ដើម្បីធ្វើយ៉ាងណាឲ្យអាគារមានក្រឡាផ្ទៃស្មើគ្នា ហើយអ្នកក្រាលព្រំ និងកម្រាល ប្រើគណិតវិទ្យាដើម្បីសម្រេចនូវចំនួនកម្រាល និងសម្ភារៈដែលត្រូវការ។ អ្នកធ្វើការក្នុងហាងត្រូវចេះគណិតវិទ្យា ដើម្បីឲ្យដឹងថាតើត្រូវអាប់លុយប៉ុន្មានទៅឲ្យអ្នកទិញ ឬត្រូវទិញសម្ភារៈប៉ុន្មាន។ មានការងាររាប់មិនអស់ ដែលពឹងផ្អែកលើគណិតវិទ្យា។
- **និយាយពីគណិតវិទ្យា។** លោកអ្នកពិតជាមានការភ្ញាក់ផ្អើលចំពោះឱកាសជាច្រើនដែលមាន។ ឧទាហរណ៍ នៅហាងលក់គ្រឿងធ្វើម្ហូប សួរកូនថា តើរបស់ណាមួយដែលថោកជាង។ ហាងជាច្រើនផ្សាយលក់របស់ចុះថ្លៃជាចំនួនភាគរយ។ សួរកូនថាតើតម្លៃចុះថោកមានចំនួនប៉ុន្មាន បើគេចុះថ្លៃ៣០%។
- **និយាយពីប្រាក់។** ក្មេងជាច្រើនទទួលប្រាក់ដែលឪពុកម្តាយឲ្យបន្តិចបន្តួច។ បើកូនលោកអ្នកទទួល សួរពួកគេថាតើឆ្នាំក្រោយប្រាក់នេះនឹងមានចំនួនប៉ុន្មានបើបង្កើន ៥%ទៀត។ និយាយជាមួយកូនជំទង់ របស់លោកអ្នកអំពីមធ្យោបាយសន្សំប្រាក់សម្រាប់ មហាវិទ្យាល័យ រថយន្ត ឬរបស់សំខាន់ៗផ្សេងទៀតដែលត្រូវទិញ។ ពិភាក្សាពីប្រាក់ចំណាយប្រចាំថ្ងៃ ដូចជា ថ្លៃឈ្នួល ថ្លៃទិញផ្ទះ ថ្លៃទឹកភ្លើង ថ្លៃទិញឡាន ថ្លៃម្ហូប និងសម្លៀកបំពាក់។ កូនលោកអ្នកអាចគូរតារាង និងពិភាក្សាពីវិធីសន្សំប្រាក់នីមួយៗ។
- **ដុតនំ។** ការដុតនំ មានរួមបញ្ចូលគណិតវិទ្យា ដូចជា ការវាល់ចំណុះ មើលពេលវេលា។ ក្មេងត្រូវដឹងរបៀបវាល់គ្រឿង តាមការប្រើរង្វាស់ត្រឹមត្រូវ ដើម្បីសម្រេចមើលទំហំចានដុតនំ និងសម្រេចថា តើចានណាមួយអាចដាក់គ្រឿងអស់។ ហើយក៏ជាការសំខាន់ដែរ ដែលត្រូវដឹងថាត្រូវដុតយូរប៉ុណ្ណា!
- **រៀនប្រើម៉ាស៊ីនគិតលេខ។** គំរូខ្នាតប្រឡងជាច្រើន រួមទាំងជំពូកខុសគ្នារបស់ PSSA អនុញ្ញាតឲ្យប្រើម៉ាស៊ីនគិតលេខ។ ជំរុញឲ្យកូន រៀនប្រើម៉ាស៊ីនគិតលេខ មុនពេលប្រឡង។ ▸▸▸

## គន្លឹះសំខាន់ៗដ៏ទៃទៀត៖

- ការធ្វើដំណើរតាមរថយន្ត។ ការជិះរថយន្តគឺជាឱកាសដ៏ល្អសម្រាប់ក្មេងបង្កើនជំនាញក្នុង ការអាន និង គណិតវិទ្យា។ អ្វីដែលល្អបំផុតគឺថា ពួកគេមិនដឹងថាពួកគេ "កំពុងរៀន" ហើយអាចជួយធ្វើឲ្យពេលវេលាលឿនទៅមុខ! ឲ្យកូនអានកន្ទុយលេខឡានខុសៗគ្នា ដែលពួកគេឃើញ ហើយកត់ទុកចំនួនសរុប។ ពួកគេអាចគូរតារាងលទ្ធផល ហើយគិតជាចំនួន ភាគរយ បង្កើតរបាក្រាហ្វិក ឬគូរពិន្ទុវេខីយ៍ចំណិត។ មានពាក្យថ្មីៗជាច្រើនដើម្បីរៀននៅពេលធ្វើដំណើរ។ ក្តារបិទប្រកាស និងសញ្ញាតាមផ្លូវ អាចជួយឲ្យក្មេងរៀនពាក្យថ្មី – រៀនពី សូរសព្ទ និងអត្ថន័យ ជាមួយកូន។ រាល់ពេល ធ្វើដំណើរ មានដំណើរកំសាន្ត ឬវិស្សមកាល ដោយមិនគិតពីចម្ងាយ បង្ហាញគំនិត ឬវត្ថុ ថ្មី ដែលកូនអាចប្រើ ដើម្បីពង្រីកវាក្យស័ព្ទរបស់ពួកគេ។

- ក្រដាសរឹងសម្រាប់សរសេរពាក្យទុកទន្ទេញ។ មានក្រដាសរឹងសម្រាប់សរសេរពាក្យទុកទន្ទេញដែលធ្វើរួចស្រេចជាច្រើនពណ៌ ដែលដាក់លក់នៅក្នុងហាង ឬបើលោកអ្នកមានគំនិតឆ្នៃប្រឌិត លោកអ្នកអាចធ្វើដោយខ្លួនឯង។ គ្រូរបស់កូនលោកអ្នកអាចឲ្យ បញ្ជីពាក្យសម្រាប់កូន ហើយលោកអ្នកត្រូវការតែ ក្រដាសរឹងសម្រាប់សរសេរ ដែលមានទំហំប្រវែង ទទឹង ៣អ៊ិង និងបណ្តោយ ៥អ៊ិង។ លោកអ្នកអាចសរសេរពាក្យសម្រាប់គណិតវិទ្យា ដូចជា "ត្រីកោណ – រាងដែលមាន៣ជ្រុង" ឬ សំណួរគណិតវិទ្យា "៤ + ៨ = ១២"។ ធ្វើអ្វីៗជាមួយកូន និងគ្រូរបស់ពួកគេ ដើម្បីគ្រោងបញ្ជីពាក្យ ឬសំណួរគណិតវិទ្យា ដែលពិបាកៗ។ ការឃើញ ការនិយាយ និងការសិក្សា ពាក្យនិងគំនិតថ្មីៗ គឺជាការសំខាន់សម្រាប់ក្មេងគ្រប់អាយុ និងគ្រប់កម្រិតថ្នាក់ទាំងអស់។

## គន្លឹះសំខាន់ៗសម្រាប់ការអាន៖

ការស្រាវជ្រាវបានបង្ហាញឲ្យឃើញថា ការអានឲ្យកូនស្តាប់នៅផ្ទះ ជួយឲ្យសិស្សរៀនពូកែនៅសាលា។ ការអានគឺជាទម្លាប់សិក្សា – មិនមែនគ្រាន់តែជាចំណេះមូលដ្ឋាន ប៉ុណ្ណោះទេ។

- **អានជាមួយកូន។** ទោះជាកូននៅក្មេងក៏ដោយក៏អាចអានជុំគ្នាបានដែរ ហើយគ្មានអ្វីដែលថាអានច្រើនហួសហេតុនោះទេ។ ការអានធ្វើឲ្យមានការអប់រំដល់ក្មេង ហើយធ្វើឲ្យមានចំណាប់អារម្មណ៍ខាង ភាសា ពាក្យ និងការទាក់ទង។ ដោយមិនគិតពីអាយុ របស់កូន គួរអានសៀវភៅជុំគ្នាមួយក្បាលក្នុងមួយខែ ហើយប្រើអ្វីៗ ដែលបានអានក្នុងសៀវភៅនេះជាឱកាស ពង្រីកការសិក្សាតាមការសន្ទនា។ កាលណាសកម្មភាពនេះមាន ដំណើរជាប្រក្រតី វានឹងជួយឲ្យការអានរបស់កូនលោកអ្នកមានការរីកចម្រើនឡើង។



- **ជំរុញឲ្យកូនបង្កើតបណ្ណាល័យសម្រាប់ខ្លួនគេផ្ទាល់។** ក្មេងចូលចិត្តតុក្កតាញាត់សំឡីរបសត្វ សៀវភៅរឿងកំប្លែង ហត្ថលេខាអ្នកល្បីៗ និង កាតបេសបាល (baseball card) បើដូច្នេះគួរតែមានការប្រមូលសៀវភៅផងដែរ! មានបណ្ណាល័យផ្ទាល់ខ្លួននឹងធ្វើឲ្យកូនលោកអ្នក មានសម្ភារៈអប់រំជាច្រើន។ បើសិនជាអាចធ្វើទៅបាន នៅពេលដើរទិញរបស់របរ គួរឆៀងចូលហាងសៀវភៅដែលនៅជិតៗនោះ ផងដែរ។

- **ឲ្យទស្សនាវដ្តីទៅកូនអំពីអ្វីៗដែលពួកគេមានចំណាប់អារម្មណ៍** មានទស្សនាវដ្តីសម្រាប់ក្មេងគ្រប់អាយុ និងគ្រប់ចំណាប់អារម្មណ៍ ទាំងអស់។ ក្មេងអាចរៀនឲ្យមានការចេះដឹងពីទស្សនាវដ្តី ហើយក្មេងធំៗអាចអានអំពីព្រឹត្តិការណ៍ថ្មីៗ និងដឹងអំពីព័ត៌មានផ្សេងៗទៀត។ និយាយជាមួយកូនអំពីអំពីទស្សនាវដ្តី ឬសេចក្តីរាយការណ៍ខ្លីៗ ដែលពួកគេអាន។

- **ទៅកាន់បណ្ណាល័យដែលនៅជិតផ្ទះលោកអ្នក។** នៅរដ្ឋផិនស៊ីលវេញ៉ា មានបណ្ណាល័យជិត៨៤០ ដែលមានបុគ្គលិកមានជំនាញផ្នែក អក្សរសិល្ប៍សម្រាប់ក្មេង ដែលសុខចិត្តផ្តល់គំនិតសម្រាប់ចំណាងជើង និងកម្មវិធីសិក្សា។ អ្វីៗដែលល្អបំផុតអំពីបណ្ណាល័យគឺ – លោកអ្នកអាចខ្ចីសៀវភៅដោយឥតបង់ថ្លៃ!

▶ ▶ ▶

## គន្លឹះដែលមានប្រយោជន៍សម្រាប់មាតាបិតា៖ វិធីជួយកូនបង្កើនចំណេះសម្រាប់ការប្រឡង PSSA (ត)

### ការត្រៀមខ្លួនដើម្បីប្រឡង៖

- ការរៀនដោយបង្ខំនៅយប់មុនថ្ងៃប្រឡងមិនមែនជារបៀបសិក្សាដែលមានប្រសិទ្ធិភាពទេ – ការសិក្សាសម្រាប់ការប្រឡងគួរធ្វើឡើងជាច្រើនថ្ងៃ ឬច្រើនសប្តាហ៍ មុនថ្ងៃប្រឡង។ កូនរបស់លោកអ្នកគួររៀនសាឡើងវិញនៅអ្វីៗដែលបានរៀនហើយ នៅយប់មុនថ្ងៃប្រឡង។ ធ្វើអ្វីៗដែលលោកអ្នកអាចធ្វើទៅបាន ដើម្បីធ្វើយ៉ាងណាឲ្យកូនធូស្រាលក្នុងខ្លួន ហើយញ៉ាំអាហារពេលល្ងាចល្អ នៅយប់មុនថ្ងៃប្រឡង។ ចាប់ផ្តើបថ្ងៃប្រឡងដោយញ៉ាំអាហារពេលព្រឹកដែលមានជីវជាតិ។ ក្មេងដែលអស់កម្លាំងមិនសូវមានសមត្ថភាពដោះស្រាយនូវភាពតានតឹងនៃការប្រឡងបានទេ ហើយប្រហែលជាមិនអាចប្រឡងបានល្អទៀតផង។
- សូមកុំធ្វើឲ្យក្មេងកាន់តែមានការលំបាក។ បើមានការសង្កត់ទៅលើពិន្ទុនៃការប្រឡងរបស់កូនខ្លាំងពេក ធ្វើឲ្យពួកគេកាន់តែខ្លាចប្រឡងធ្លាក់ ហើយធ្វើឲ្យពួកគេកាន់តែបារម្ភនៅពេលប្រឡង – អាចបង្កើនឲ្យមានការខុសឆ្គងកាន់តែច្រើន។ បន្ថយភាពតានតឹងនៃការប្រឡង របស់លោកអ្នកនិងកូនដោយនិយាយតែអំពីអ្វីៗដែលល្អ។ កូនរបស់លោកអ្នកនឹងដឹងពី ជំនឿល្អៗរបស់លោកអ្នក ហើយមានការទុកចិត្តលើខ្លួនឯងកាន់តែខ្លាំងឡើង។

## សំណួរដែលគេឧស្សាហ៍សួរ

**សំណួរ៖ តើ PSSA ជាអ្វី?**

- PSSA ជំនួសពាក្យ ប្រព័ន្ធវាយតម្លៃសាលារបស់រដ្ឋផិនស៊ីលវេញ៉ា – ជាការវាយតម្លៃទូទាំងរដ្ឋពី គណិតវិទ្យា ការអាន ការសរសេរ និង វិទ្យាសាស្ត្រ ដែលចេញមួយឆ្នាំម្តង នៅគ្រប់ក្រសួងអប់រំ និង សាលាឆាទ័រ ទាំងអស់ ក្នុងរដ្ឋផិនស៊ីលវេញ៉ា ដើម្បីប្រមាណមើលជោគជ័យ របស់សីស្ស តាមគំរូសិក្សានៅរដ្ឋផិនស៊ីលវេញ៉ា។

**សំណួរ៖ តើគោលបំណងនៃការប្រឡង PSSA គឺដើម្បីអ្វី?**

- ផ្តល់ឲ្យ សិស្ស មាតាបិតា បញ្ញវន្ត និង ពលរដ្ឋ នូវការយល់ដឹងអំពីការអប់រំរបស់ សិស្ស និង សាលា។
- សម្រេចមើលកម្រិតកម្មវិធីសាលាដែលជួយសិស្សឲ្យទទួលការប៉ិនប្រសប់តាមគំរូសិក្សា។

**សំណួរ៖ តើសិស្សណាខ្លះដែលត្រូវមានការវាយតម្លៃមើល?**
លើកលែងតែសិស្សមួយចំនួនតូចដែលត្រូវតាមកល្ខណៈវិនិច្ឆ័យណាមួយ សម្រាប់ការចូលរួមក្នុងការវាយតម្លៃផ្សេងទៀត សិស្សទាំងអស់ត្រូវគេតម្រូវឲ្យមានការវាយតម្លៃ ដូចបានពន្យល់ខាងក្រោមនេះ៖

- ការអាន និង គណិតវិទ្យា – ថ្នាក់ទី ៣ ៤ ៥ ៦ ៧ ៨ និង ១១
- ការសរសេរ – ថ្នាក់ទី ៥ ៨ និង ១១
- ចំណេះវិទ្យាសាស្ត្រ – ថ្នាក់ទី ៤ ៨ និង ១១

**សំណួរ៖ តើការវាយតម្លៃត្រូវចំណាយពេលយូរប៉ុណ្ណា?**

- ការវាយតម្លៃ ការអាន និងគណិតវិទ្យា ទាំងមូល ត្រូវចំណាយពេលប្រហែល ប្រាំមួយទៅប្រាំពីរម៉ោង ទើបធ្វើចប់។ បញ្ចប់ការវាយតម្លៃទាំងមូល ត្រូវចំណាយពេលប្រហែល បួនទៅប្រាំមួយម៉ោង។ ការវាយតម្លៃផ្នែក ចំណេះវិទ្យាសាស្ត្រ ត្រូវចំណាយពេលប្រហែល ពីរទៅបួនម៉ោង។
- តាមធម្មតា ការវាយតម្លៃត្រូវធ្វើឡើងក្នុងរយៈពេលជាច្រើនថ្ងៃ។ សាលារបស់លោកអ្នកគួរផ្តល់ដំណឹងដល់លោកអ្នកអំពី កាលវិភាគនៃការវាយតម្លៃនេះ។

**សំណួរ៖ តើមាតាបិតាអាចធ្វើអ្វី ដើម្បីធ្វើយ៉ាងណាឲ្យកូនត្រៀមខ្លួនជាស្រេចនៅថ្ងៃប្រឡង?**

- កត់ថ្ងៃប្រឡងទុកក្នុងប្រតិទិន ដើម្បីឲ្យលោកអ្នកនិងកូនដឹងពីថ្ងៃទ្រឡង។
- ធ្វើយ៉ាងណាឲ្យកូនទៅរៀននៅថ្ងៃប្រឡង។ សូមកុំធ្វើការណាត់ជួបជាមួយ វេជ្ជបណ្ឌិត ពេទ្យធ្មេញ ឬការណាត់ជួបផ្សេងទៀត នៅថ្ងៃប្រឡង។
- សូមកុំអន្ទះអន្ទែងខ្លាំងពេកអំពីពិន្ទុនៃការប្រឡង ប៉ុន្តែត្រូវជំរុញកូនឲ្យខំអស់ពីសមត្ថភាព។
- ឲ្យកូនសម្រាកពីរបីម៉ោងមុនចូលគេង ហើយធ្វើយ៉ាងណាឲ្យកូនគេងឲ្យបានគ្រប់គ្រាន់នៅយប់មុនថ្ងៃប្រឡង។
- ធ្វើយ៉ាងណាឲ្យកូនញ៉ាំអាហារពេលព្រឹកដែលមានជីវជាតិ ហើយជៀសវាងកុំញ៉ាំអាហារដែលធ្វើឲ្យធ្ងន់ពោះខ្លាំងពេកនៅព្រឹកដែលត្រូវប្រឡង។
- ជំរុញឲ្យកូនស្តាប់ការណែនាំនៃការប្រឡងដោយប្រុងប្រយ័ត្ន ហើយ សួរសំណួរពេលណាមិនច្បាស់។
- ជួយកុំឲ្យកូនភ័យព្រួយ ដោយជំរុញឲ្យពួកគេព្យាយាមប្រឡងឲ្យអស់ពីសមត្ថភាព។

### គន្លឹះនៃការប្រឡង សម្រាប់សិស្ស

- **ធ្វើលំហាត់ និងកិច្ចការសាលាឲ្យបានរួចរាល់ទាន់ពេល។** កិច្ចការសាលានឹងជួយអ្នកឲ្យត្រៀមខ្លួនសម្រាប់ប្រឡង។
- **គេងឲ្យបានច្រើន**នៅយប់មុនថ្ងៃប្រឡង។
- **ញ៉ាំអាហារពេលព្រឹកដែលមានជីវជាតិ**នៅថ្ងៃប្រឡង។
- យកសៀវភៅ ឬសម្ភារៈមកអានស្ងាត់ៗ ក្នុងគ្រាដែលអ្នកប្រឡងចប់ មុនពេលកំណត់។
- នៅពេលប្រឡង **សូមអានការណែនាំដោយប្រុងប្រយ័ត្ន**។ បើសិនជាអ្នកមិនយល់ការណែនាំ សូមលើកដៃ ហើយ**សុំឲ្យគ្រូរបស់អ្នក**ពន្យល់សំណួរទាំងនោះ។
- បើសិនជាមានសំណួរណាដែលអ្នកមិនអាចឆ្លើយបាន **រំលងសំណួរនោះ ហើយចាំត្រឡប់ទៅឆ្លើយសំណួរនោះវិញ**។ អ្នកក៏អាចឆ្លើយតាមការស្មានដោយទម្លាក់ចោលនូវចម្លើយណាដែលអ្នកគិតថាខុស។
- អានសំណួរ និងចម្លើយ។ ត្រឡប់ទៅមើលអត្ថបទវិញដើម្បីរកមើលចម្លើយដែលត្រូវ។
- **អានចម្លើយនីមួយៗ មុននឹងជ្រើសរើសយកចម្លើយចុងក្រោយ**។
- **ពិនិត្យមើលចម្លើយរបស់អ្នកឡើងវិញ ដើម្បីឲ្យដឹងថាអ្នកបានបំពេញចម្លើយដែលត្រូវ**។
- នៅពេលដែលអ្នកប្រឡងចប់ សូមមើលទំព័រទាំងអស់ ដើម្បីឲ្យដឹងថាអ្នកបានឆ្លើយសំណួរទាំងអស់។
- នៅចុងបញ្ចប់នៃការប្រឡង ធ្វើអ្វីៗដោយស្ងៀមស្ងាត់។ សូមចាំថា មិត្តរួមថ្នាក់របស់អ្នកប្រហែលជាកំពុងតែប្រឡង។
- **សូមកុំបារម្ភអ្វី! គ្រាន់តែប្រឹងឲ្យអស់ពីសមត្ថភាពទៅបានហើយ**។

### វិធីសាស្ត្រសម្រាប់ឆ្លើយ សំណួរដែលមានចម្លើយសម្រាប់ជ្រើសរើស

- **អានសំណួរនីមួយៗដោយប្រុងប្រយ័ត្ន។** កុំស្មានថាអ្នកដឹងចម្លើយ មុនពេលដែលអ្នកយល់សំណួរដែលគេបានសួរ។
- **សំណួរសម្រាប់ជ្រើសរើសនីមួយៗ** (ក្នុងមុខវិទ្យាជាអ្វីក៏ដោយ - ការអាន គណិតវិទ្យា ការសរសេរ ឬចំណេះវិទ្យាសាស្ត្រ) ត្រូវបានមួយពិន្ទុ។
- បើសិនជាអ្នកមិនដឹងចម្លើយទៅនឹងសំណួរសម្រាប់ជ្រើសរើស សូមប្រើវិធីសាស្ត្រទម្លាក់ចោលដូចបានពន្យល់ខាងក្រោមនេះ។
- បើសិនជាអ្នកមិនអាចឆ្លើយសំណួរបាន សូមរំលងចោលចាំត្រឡប់មកឆ្លើយនៅពេលក្រោយ។
- **សូមកុំបង្អង់ ហើយឆ្លើយសំណួរទាំងអស់។ គ្មានចម្លើយណាដូចគ្នា នឹងចម្លើយដែលខុសទេ។**

## វិធីទម្លាក់ចោល - ត្រូវចាប់ផ្ដើមពីត្រង់ណា នៅពេលដែលអ្នកមិនច្បាស់

វិធីទម្លាក់ចោលគឺជាវិធីសាស្ត្រដែលមានប្រយោជន៍ ក្នុងការឆ្លើយសំណួរសម្រាប់ជ្រើសរើស។

មុនពេលមើលចម្លើយសម្រាប់ជ្រើសរើស សិស្សគួរសាកទាយមើលថាតើ ចម្លើយណាជាចម្លើយដែលត្រូវ។ នៅពេលដែលពួកគេមានភាពលំបាកក្នុងការទាយ ពួកគេអាចប្រើវិធីសាស្ត្រទម្លាក់ចោល ដើម្បីទម្លាក់ចោលនូវចម្លើយណាដែលខុស។

ពេលដែលទម្លាក់ជម្រើសរួចហើយ ការរកមើលចម្លើយដែលត្រូវ មានកាន់តែច្រើន។ នេះគឺជាវិធីធ្លាប់ដឹងនូវប្រភេទខុសៗគ្នាពីចម្លើយដែលខុសខាងក្រោមនេះអាចជួយសិស្សបង្កើនពិន្ទុនៃការប្រឡងរបស់ពួកគេ។

ប្រភេទនៃចម្លើយដែលខុស មាន៖

- **ជម្រើសភាសាដែលហួសប្រមាណ** ទម្លាក់ចោលចម្លើយដែលប្រើភាសាហួសប្រមាណ (មិនដែល តែងតែ គ្មានទាំងអស់ ល្អបំផុត និងអាក្រក់បំផុត) អារម្មណ៍ដែលហួសប្រមាណ និង ប្រតិកម្មដែលរំភើបចិត្តខ្លាំង។
- **ការជ្រើសរើស ដែលមានកម្រិត/ទូលំទូលាយ** ជម្រើសខ្លះ សំដៅទៅលើតែមួយជំពូក ▸▸▸ មិនមែនវគ្គទាំងមូល ហើយជម្រើសផ្សេងទៀតប្រហែល

ជាមានព័ត៌មានដែលទូលំទូលាយ ឬទូទៅ ហួសប្រមាណ។ បំបាត់ចោលនូវចម្លើយណាដែលមានកម្រិត ឬទូលំទូលាយ ហួសប្រមាណ។

- **ជម្រើស ពិត ប៉ុន្តែ**...

  ជម្រើសខ្លះមានព័ត៌មានដែលពិត ប៉ុន្តែមិនឆ្លើយនឹងសំណួរដែលបានសួរ។ ទម្លាក់ចោលនូវជម្រើសដែលពិត តែមិនឆ្លើយនឹងសំណួរ។

- **ជម្រើសដែលផ្ទុយ**

  ទម្លាក់ចោលនូវជម្រើសដែលផ្ទុយនឹងវគ្គ។ ជ្រើសរើសចម្លើយបែបនេះបើសិនជាពាក្យ "**មិនមែន**" ឬ "**លើកលែងតែ**" មាននៅក្នុងសំណួរ។

## ការវាយតម្លៃ ការអាន

- ការវាយតម្លៃការអាន បកស្រាយនូវជំនាញធំពីរប្រភេទ ដែលជាប់ទាក់ទងនឹងវិធីនៃការសរសេរៈ ១, ការអាន និងជំនាញនៃការយល់ដឹង ២, សមត្ថភាពធ្វើវិភាគនិង បកស្រាយនូវអ្វីៗដែលយើងបានអាន។
- ក្នុងកំឡុងពេលស្ទង់មើលការអាន សិស្សត្រូវបានគេឲ្យវគ្គជាច្រើនពី រឿងប្រឌិត និងរឿងពិត ហើយត្រូវសុំឲ្យឆ្លើយសំណួរ អំពីវគ្គទាំងនេះ។ ដោយឆ្លើយសំណួរទាំងនេះ សិស្សបង្ហាញនូវការយល់ដឹង និងជំនាញ ក្នុងការអាន និងការធ្វើវិភាគរបស់ពួកគេ និងការបកស្រាយពីសៀវភៅរឿងប្រឌិត និងរឿងពិត។

## ប្រភេទនៃវគ្គ សម្រាប់គោលដៅនៃការអាន តាមកម្រិតថ្នាក់

**ប្រភេទនៃវគ្គ សម្រាប់គោលដៅនៃការអាន សម្រាប់ថ្នាក់ទី៣**

- រឿង ២
- កំណាព្យ ១
- អត្ថបទព័ត៌មាន ១
- ជីវប្រវត្តិផ្ទាល់ខ្លួន/ ជីវប្រវត្តិ ១ ឬ អត្ថបទដែលមានប្រយោជន៍/វិធីធ្វើអ្វីមួយ/ការផ្សព្វផ្សាយ ១

**ប្រភេទនៃវគ្គ សម្រាប់គោលដៅនៃការអាន សម្រាប់ថ្នាក់ទី ៣-៨ និង ១១** (ការលាយឡំខុសៗគ្នា ទៅតាមកម្រិតថ្នាក់)

- រឿង (គ្រប់ថ្នាក់ទាំងអស់)
- កំណាព្យ (គ្រប់ថ្នាក់ទាំងអស់)
- អត្ថបទព័ត៌មាន* (គ្រប់ថ្នាក់ទាំងអស់)
- ជីវប្រវត្តិផ្ទាល់ខ្លួន/ ជីវប្រវត្តិ (គ្រប់ថ្នាក់ទាំងអស់)
- អត្ថបទដែលមានប្រយោជន៍/វិធីធ្វើអ្វីមួយ/ការផ្សព្វផ្សាយ
- តែងសេចក្តី/វិចារណកថា (ថ្នាក់ទី ៥ ៦ ៧ ៨ និង ១១)

* អត្ថបទព័ត៌មានអាចជា ទំព័រវិបសៃ សម្រាប់ថ្នាក់ទី៦-៨ និង ១១។

## សំណួរដែលត្រូវឆ្លើយតាមគំនិតរបស់ខ្លួន - ការអាន

សំណួរ PSSA ដែលត្រូវឆ្លើយតាមគំនិតរបស់ខ្លួនសម្រាប់ការអាន សុំឲ្យសិស្សរៀបចំចម្លើយរបស់ពួកគេ តាមគំនិតរបស់ខ្លួន**ខ្លីៗ ច្បាស់លាស់ ផ្តោតទៅលើអត្ថន័យនៃអត្ថបទ** (ឧ. សង្ខេប បង្ហាញ ពន្យល់ និងវិភាគ)

សូមចាំថា **ការវាយតម្លៃការអានមិនមែនស្ទង់មើលជំនាញនៃការសរសេររបស់សិស្សទេ**។

## វិធីសាស្ត្រសម្រាប់ឆ្លើយសំណួរ ដែលត្រូវផ្តល់ចម្លើយតាមគំនិតរបស់ខ្លួន (បង្កើតគំនិតឆ្លើយ)

- អានចម្លើយតាមការប្រឌិតឡើង ឬ "អត្ថបទ" សំណួរ មុននឹងចាប់ផ្តើមអានវគ្គ។
- អានសំណួរដោយប្រុងប្រយ័ត្ន។ យកចិត្តទុកដាក់លើចំណុចរំលឹក។
- ផាត់ពណ៌ឬគូរបន្ទាត់ពីក្រោម អ្វីៗដែលគេសុំឲ្យអ្នកធ្វើ ដូចជាពាក្យៈ
  - ➢ សូមពន្យល់ពីគំនិតសំខាន់ៗ
  - ➢ សូមពណ៌នាពីតួអង្គ
  - ➢ សូមប្រើឧទាហរណ៍៣ ពីវគ្គដែលបានអាន
- រក្សាទុកនូវ ចម្លើយតាមការប្រឌិតឡើង នៅក្នុងខួរក្បាលរបស់អ្នក នៅពេលដែលអ្នកកំពុងអាន។
- ក្នុងពេលកំពុងអាន អ្នកអាចគូសសម្គាល់ក្នុងវគ្គ ដែលអ្នកអាចប្រើ ក្នុងចម្លើយរបស់អ្នក។
- ប្រើពាក្យដែលបានរក្សាទុកក្នុងខួរក្បាលដើម្បីសរសេរឃ្លាដែលជាគោលគំនិត។
- ឆ្លើយសំណួរគ្រប់ផ្នែកទាំងអស់។
- រួមទាំងការរៀបរាប់យ៉ាងល្អិតល្អន់ពីវគ្គ។
- ធ្វើឲ្យមានការតភ្ជាប់ ដោយរួមបញ្ចូលគំនិតរបស់អ្នកផ្ទាល់។
- សរសេរឲ្យស្អាត ហើយច្បាស់លាស់។ ប្រើតែកន្លែងសរសេរដែលគេបានផ្តល់ឲ្យ។ បញ្ជាក់ឲ្យអ្នកអានរបស់អ្នកថា អ្នកយល់ច្បាស់ពីវគ្គនេះ។

## វិធីសាស្ត្រ សម្រាប់ការអាន

**គូសរង្វង់ជុំវិញ (ផាត់ពណ៌ចំណាំ) ពាក្យណែនាំ (កិរិយាស័ព្ទ)។**

ឧទាហរណ៍៖ អាន សរសេរ កត់បញ្ជី គាំទ្រ បង្ហាញភស្តុតាងត្រឹមត្រូវ

**គូសបន្ទាត់ពីក្រោម ពាក្យសំខាន់ៗ ក្រោយពាក្យណែនាំ។**

ពាក្យសំខាន់ៗសម្រាប់ឆ្លើយសំណួរ៖ របៀបណា អ្វី ទីណា

**រាប់ចំនួនពាក្យណែនាំ** (១ ២ ៣ …)

**គូស អ្វីៗ ដែលអ្នកបានធ្វើរួចហើយ។** (✓)

## ឧទាហរណ៍

1✓ 2✓ 3✓

Read the story. Explain the mood created by the author. Use examples from the story to show how the author creates the mood.

## វិធីសាស្ត្រសម្រាប់ឆ្លើយសំណួរដែលត្រូវឆ្លើយតាមគំនិតរបស់ខ្លួន ផ្ដោតលើ “៣” ចំណុច

**បង្វែរសំណួរ ឲ្យទៅជាប្រយោគ** (១)

**ឆ្លើយសំណួរ ដែលគេសួរ** (២)

**ផ្ដល់ ព័ត៌មានលម្អិត ភស្តុតាង និងឧទាហរណ៍ ពីក្នុងអត្ថបទ ដើម្បីគាំទ្រចម្លើយរបស់អ្នក**(៣)

## ឧទាហរណ៍

ឲ្យពាក្យ ឬឃ្លាដែលពណ៌នាពីសិស្សនិងអ្នកតំណាងសាលា។ ប្រើយ៉ាង ហោចណាស់ឧទាហរណ៍មួយពីវិចារណកថា ដើម្បីពន្យល់ចម្លើយរបស់ អ្នក។

*ពាក្យដែលខ្ញុំនឹងប្រើ ដើម្បីពណ៌នាពីសិស្សនិងអ្នកតំណាងសាលា គឺ សមហេតុសមផល។*

*ឧទាហរណ៍របស់សិស្សដែលសមហេតុសមផលគឺ គេបាននិយាយថា ត្រូវការទូរស័ព្ទដៃ សម្រាប់សន្តិសុខ។ មាតាបិតាប្រហែលជាត្រូវការទាក់ទងទៅកូននៅពេលមានអាសន្ន។*

*អ្នកតំណាងសាលាក៏មានការសមហេតុសមផលនៅពេលដែលគាត់និយាយថា ទូរស័ព្ទដៃនៅក្នុងថ្នាក់នឹងបណ្ដាលឲ្យមានការរំខាន ដោយសារក្មេងនឹងភ្លេចបិទទូរស័ព្ទ។*

## ការធ្វើវិភាគ

✓ក្នុងចម្លើយសិស្សប្រើចំណុច ដើម្បីសរសេរឃ្លាដែលជាគោលគំនិត។

✓សិស្សធ្វើតាមការណែនាំដែលគេបានផ្ដល់ឲ្យ។

✓សិស្សផ្ដល់ឧទាហរណ៍ដែលសមរម្យពីអត្ថបទ ដើម្បីពន្យល់នូវចំណុចរបស់ខ្លួន។

### គោលការណ៍ណែនាំពីការឲ្យពិន្ទុសម្រាប់ចម្លើយតាមគំនិតរបស់ខ្លួន របស់ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា

៣ពិន្ទុ

- ការឆ្លើយតបផ្ដល់នូវចម្លើយយ៉ាងពេញលេញទៅនឹងកិច្ចការដែលដាក់ឲ្យធ្វើ ឧ. សេចក្ដីរាយការណ៍ដែលផ្ដល់ចម្លើយត្រូវព្រមទាំងការគាំទ្រអត្ថបទ។
- ការឆ្លើយតបផ្ដល់ឲ្យបានល្អិតល្អន់ ចំៗ សមរម្យ និងត្រឹមត្រូវ (ឧ. ឲ្យឈ្មោះ ពណ៌នា ពន្យល់ ឬប្រៀបធៀប) ឬឧទាហរណ៍។

២ពិន្ទុ

- ការឆ្លើយតបផ្ដល់នូវចម្លើយដែលមិនពេញលេញទៅនឹងកិច្ចការដែលដាក់ឲ្យធ្វើ ឧ. បញ្ជាក់នូវការយល់ដឹងខ្លះៗពីកិច្ចការដែលដាក់ឲ្យធ្វើ ហើយយ៉ាងហោចណាស់មានអត្ថបទល្អិតល្អន់មួយ។
- ការឆ្លើយតបព្យាយាមផ្ដល់ឲ្យបានល្អិតល្អន់ គ្រប់គ្រាន់ សមរម្យ (ឧ. ឲ្យឈ្មោះ ពណ៌នា ពន្យល់ ឬប្រៀបធៀប) ឬឧទាហរណ៍។ ប្រហែលជាមានការមិនត្រឹមត្រូវបន្តិចបន្តួច។

១ពិន្ទុ

- ការឆ្លើយតបផ្ដល់ចម្លើយមិនពេញលេញទៅនឹងកិច្ចការដែលដាក់ឲ្យធ្វើ ឧ. បញ្ជាក់នូវការមិនយល់ដឹង ឬគ្មានអត្ថបទល្អិតល្អន់។
- ការឆ្លើយតបផ្ដល់ចម្លើយមិនបានល្អិតល្អន់ សមរម្យ ឬឧទាហរណ៍ ដែលធ្វើមិនត្រឹមត្រូវ។

០ពិន្ទុ

- ការឆ្លើយតបផ្ដល់ចម្លើយមិនគ្រប់គ្រប់សម្រាប់ឲ្យពិន្ទុ។
- ការឆ្លើយតបផ្ដល់ចម្លើយខុសទាំងអស់។

# ការវាយតម្លៃផ្នែក គណិតវិទ្យា

## តើការប្រឡងមានអ្វីខ្លះ?

ការប្រឡងផ្នែកគណិតវិទ្យាមានប្រាំប្រភេទនៅលើ PSSA សម្រាប់ថ្នាក់ទី ៣-៨ និង ទី១១ ទាំងអស់៖

- A. លេខ និង ប្រមាណវិធីទាំងបួន
- B. រង្វាស់
- C. ធរណីមាត្រ
- D. ពិជគណិត
- E. ការវិភាគទិន្នន័យ និងស្ថិតិ

**អ្នកអាចឃើញគំរូដោះស្រាយលំហាត់ និងដំណោះស្រាយសម្រាប់ថ្នាក់នីមួយៗ ក្នុងសំណួរគណិតវិទ្យា និងគំរូឲ្យពិន្ទុ។** សូមមើល "ជំនួយក្នុងការត្រៀមខ្លួនប្រឡងតាមវិបសៃ – Test Preparation Web Resources" ខាងលើ សម្រាប់ការណែនាំក្បោះក្បាយ។

## វិធីសាស្ត្រគណិតវិទ្យា

**អានសំណួរនីមួយៗដោយប្រុងប្រយ័ត្ន ហើយឆ្លើយឲ្យចំៗនូវអ្វីៗដែលបានសួរ។**

## លំដាប់នៃប្រមាណវិធី

**()** វង្ងង់ក្រចក*
(*ឬសញ្ញាដទៃទៀតនៃសំណុំនីមួយៗ។ ចាប់ផ្តើមពីខាងក្នុងបំផុតទៅ () )

**$Y^x$** និទស្សន្ត

**x** គុណ **
**/** ចែក **
(**អាច ចែក ឬ គុណ មួយណាមុនក៏បាន)

**+** បូក ***
**-** ដក ***
(***អាច ដក ឬ បូក មួយណាមុនក៏បាន)

## ចំបែកពាក្យសម្ងាត់សម្រាប់គណិតវិទ្យា

ប្រើគន្លឹះវាក្យស័ព្ទដើម្បីជួយអ្នកឲ្យសម្រេចថាត្រូវប្រើ ប្រមាណវិធីទាំងបួន

| **បូក** | **ដក** |
|---|---|
| add | are not |
| altogether | change |
| and | decreased by |
| both | difference |
| how many | fewer |
| how much | have left |
| in all | how many didn't |
| increased by | how many more |
| more | how much more |
| plus | less than |
| sum | remains |
| together | subtract |
| total | take away |
| **ចែក** | taller/shorter |
| cut into | **គុណ** |
| divided by | altogether |
| each group has | by |
| half / equal parts | double |
| quotient of | each |
| separated | multiplied by |
| share equally | product of |
| split | times |

## វិធីសម្រាប់ដោះស្រាយ គណិតវិទ្យា

- **យកសំណួរមកធ្វើផ្ទាល់ គិតក្នុងចិត្ត ឬប្រើរបស់អ្វីមួយ**
- **គូររូប ឬគូរខ្សែបន្ទាត់ សម្រាប់ពន្យល់**
- **គូរតារាង ឬផែនទី**
- **ធ្វើបញ្ជី**
- **ស្មាន និងពិនិត្យមើល**
- **ធ្វើត្រឡប់ទៅក្រោយវិញ**
- **រកមើលលំនាំ**
- **ធ្វើឲ្យងាយស្រួល**
- **គិតម៉ែកញ្ញែក**

## សំណួរដែលត្រូវឆ្លើយតាមគំនិតរបស់ខ្លួន - គណិតវិទ្យា

### ឧទាហរណ៍ ពីរបៀបសួរ ដែលគេអាចសួរសំណួរដែលត្រូវឆ្លើយតាមគំនិតរបស់ខ្លួន៖

- បង្ហាញ ឬពន្យល់ ពីចម្លើយទាំងអស់ ដែលអ្នកបានឆ្លើយ។
- បង្ហាញរបៀបធ្វើទាំងអស់របស់អ្នក។ ពន្យល់ពីមូលហេតុដែលអ្នកបានធ្វើ នូវជំណាក់កាលនីមួយៗ។
- ពន្យល់ ហេតុអ្វីបានជាវា ពិត ឬមិនពិត។
- រៀបរាប់ពីការធ្វើអ្វីមួយ ដែលអាចប៉ះពាល់ដល់អ្វីផ្សេងទៀត។
- រៀបរាប់ពីវិធីដែលអាចដោះស្រាយបញ្ហា។

### វិធីសាស្ត្រគណិតវិទ្យា ពីរក្រឡាន សម្រាប់ឆ្លើយសំណួរគណិតវិទ្យាតាមគំនិតរបស់ខ្លួន

១. អានសំណួរ

២. ចែកក្រដាសរបស់អ្នកឲ្យទៅជាពីរក្រឡាន
▶សរសេរផ្លាកនៅជួរខាងឆ្វេង "កិច្ចការ"
▶ សរសេរផ្លាកនៅជួរខាងស្តាំ "ការពន្យល់"

៣. សរសេរលេខសម្រាប់ការធ្វើគណិតវិទ្យារបស់ អ្នកមួយជំណាក់ៗ និងការពន្យល់ដែលត្រូវគ្នា

៤. ធ្វើពីម្ខាងទៅម្ខាងទៀត
▶ធ្វើលើកទីមួយ សរសេរពីការពន្យល់។
▶ ធ្វើបន្ទាប់ទៀត ។ល។

៥. ជៀសវាងកុំប្រើលេខក្នុងជួរដែលពន្យល់

៦. សរសេរពន្យល់អំពីចម្លើយ

បានសម្របសម្រួលដោយលោក Jeffery Kodroff 2002

### គោលការណ៍ណែនាំពីការឲ្យពិន្ទុទូទៅសម្រាប់គណិតវិទ្យា តាមចម្លើយតាមគំនិតរបស់ខ្លួន របស់ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា

៤ពិន្ទុ
ការឆ្លើយតបបង្ហាញឲ្យឃើញនូវការយល់ដឹងច្បាស់អំពី គណិតវិទ្យា និងវិធីផ្សេងៗ ដែលបានតម្រូវដោយកិច្ចការដែលបានដាក់ឲ្យធ្វើនេះ។

- ការឆ្លើយតបផ្តល់ចម្លើយដែលត្រូវបានបង្ហាញនូវវិធីគណិតវិទ្យាដែលច្បាស់លាស់ និងពេញលេញ និងការពន្យល់ដែលត្រឹមត្រូវតាមការតម្រូវរបស់កិច្ចការដែលបានដាក់ឲ្យធ្វើ។

៣ពិន្ទុ
ការឆ្លើយតបបង្ហាញឲ្យឃើញនូវការយល់ដឹងទូទៅអំពី គណិតវិទ្យា និងវិធីផ្សេងៗ ដែលបានតម្រូវដោយកិច្ចការដែលបានដាក់ឲ្យធ្វើនេះ។

- ការឆ្លើយតប និងការពន្យល់ តាមការតម្រូវរបស់កិច្ចការដែលបានដាក់ឲ្យធ្វើ ភាគច្រើនត្រឹមត្រូវ ហើយពេញលេញ។ ការឆ្លើយតបប្រហែលជាខុសតិចតួច ឬមិនបានធ្វើ ដែលមិនបង្ហាញពីការយល់ដឹងទូទៅ។

២ពិន្ទុ
ការឆ្លើយតបបង្ហាញឲ្យឃើញនូវការយល់ដឹងខ្លះៗអំពី គណិតវិទ្យា និងវិធីផ្សេងៗ ដែលបានតម្រូវដោយកិច្ចការដែលបានដាក់ឲ្យធ្វើនេះ។

- ការឆ្លើយតបត្រូវខ្លះ ជាមួយនឹងការយល់ដឹងខ្លះៗ នៃការតម្រូវរបស់ គណិតវិទ្យា និង/ឬ វិធីផ្សេងៗដែលបានបង្ហាញ និង/ឬ បានពន្យល់។ ការឆ្លើយតបប្រហែលជាមានកិច្ចការខ្លះដែលធ្វើចប់ ឬមិនច្បាស់។

១ពិន្ទុ
ការឆ្លើយតបបង្ហាញឲ្យឃើញនូវការយល់ដឹងតិចបំផុតអំពី គណិតវិទ្យា និងវិធីផ្សេងៗ ដែលបានតម្រូវដោយកិច្ចការដែលបានដាក់ឲ្យធ្វើនេះ។

០ពិន្ទុ
ការឆ្លើយតបគ្មានចម្លើយដែលត្រូវសោះ ហើយគ្មានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញថាមានការយល់ដឹងទាល់តែសោះអំពី គណិតវិទ្យា និងវិធីផ្សេងៗ ដែលបានតម្រូវដោយកិច្ចការដែលបានដាក់ឲ្យធ្វើ សម្រាប់កម្រិតថ្នាក់នោះ។

- ការឆ្លើយតបប្រហែលជាបង្ហាញតែព័ត៌មានដែលបានចម្លងពីសំណួរ តែប៉ុណ្ណោះ។

# ការយល់ដឹងអំពី ប្រមាណវិធី នៃគណិតវិទ្យា

## បូក

យើងប្រើលេខបូកនៅពេលណាយើងដាក់ចំនួនផ្សេងៗចូលគ្នា។ ឧបមាថា យើងដាក់របស់ទៅលើគំនរ។ នៅពេលដែលយើងដាក់បន្ថែមរបស់មួយ ឬរបស់ជាច្រើន យើងប្រើលេខបូក។

ឧបមាថា យើងមានកូនបីនាក់ដែលបានយកសៀវភៅទៅសាលា ដើម្បីឲ្យទៅបណ្ណាល័យនៅក្នុងថ្នាក់រៀន។ Mary បានយកសៀវភៅមក ៥ក្បាល John បានយកសៀវភៅមក ២ក្បាល Jeremaya បានយកសៀវភៅមក ៨ក្បាល តើយើងអាចធ្វើដូចម្ដេចទើប ដឹងថាបណ្ណាល័យបានទទួលសៀវភៅប៉ុន្មានក្បាល? យើងត្រូវបូកលេខទាំងអស់៖ ៥ + ២ + ៨ = ១៥។

## ដក

យើងប្រើលេខដកនៅពេលណាយើងដកយកអ្វីៗចេញ។ រាល់ពេលដែលយើងដករបស់អ្វីមួយ ឬរបស់ជាច្រើន យើងប្រើលេខដក។

ឥឡូវនេះ បណ្ណាល័យរបស់យើងមានសៀវភៅ ១៥ក្បាល យើងមានសិស្ស២នាក់ខ្ចីសៀវភៅ។ Lisa ខ្ចីសៀវភៅ៣ក្បាល ហើយ Aaron ខ្ចីសៀវភៅ ២ក្បាល

តើឥឡូវនេះយើងនៅសល់សៀវភៅប៉ុន្មានក្បាលទៀត? យើងត្រូវដកសៀវភៅដែលបានខ្ចីចេញ៖ ១៥– ៣ – ២ = ១០។

## គុណ

យើងប្រើលេខគុណនៅពេលណាយើងបូកចំនួនរបស់ដូចគ្នាច្រើនដង។

ឧទាហរណ៍ ជំនួសពីការយកសៀវភៅតាមចំនួនខុសៗគ្នាមក សិស្សរបស់យើងយកសៀវភៅតាមចំនួនដូចៗគ្នា៖ Mary បានយកសៀវភៅមក ៥ក្បាល John បានយកសៀវភៅមក ៥ក្បាល Jeremaya បានយកសៀវភៅមក ៥ក្បាល។ តើបណ្ណាល័យរបស់យើងបានទទួលសៀវភៅប៉ុន្មានក្បាល នៅពេលនេះ? ដើម្បីឆ្លើយនឹងសំណួរនេះ យើងអាចបូកប្រាំ បីដង (៥ + ៥ + ៥ ) ឬយើងអាចគុណលេខប្រាំជាមួយនឹងចំនួនរបស់ដែលយើងបានបូកចំនួនដូចគ្នា (៥ x 3 ) ចម្លើយគឺនៅតែ១៥ដដែល។

## ចែក

លេខចែកក៏ទាក់ទងនឹងស្ថានការណ៍នៅពេលណាដែលយើងបូកចំនួនដូចគ្នាជាច្រើនដង លើកលែងតែ ពេលនេះយើងដឹងពីលទ្ធផល (លទ្ធផល)។ ប៉ុន្មានក្បាលមក។ យើងត្រូវចែក១៥ ជា ៣ចំណែកស្មើៗគ្នា៖ ១៥/៣ = ៥។

តាមការជ្រើសរើសផ្សេងទៀត យើងបានសម្រេចចិត្តថាការឲ្យសៀវភៅ៥ក្បាល អាចផ្ដល់ឲ្យសិស្សនូវឱកាសចូលរួមក្នុងឆ្នោតវត្ថុ។ ពេលនេះ យើងចង់សម្រេចមើលចំនួនសិស្សដែលត្រូវចូលរួម ដើម្បីឲ្យយើងអាចសម្រេចតាមគោលបំណងរបស់យើង នៃចំនួនសៀវភៅ១៥ក្បាល៖ ១៥/៥ = ៣។

## ប្រភាគ

មធ្យោបាយល្អក្នុងការមើលប្រភាគគឺគិតដល់ការកាត់នំឲ្យទៅជាដុំៗស្មើគ្នា ហើយបន្ទាប់មកយកដុំនំទាំងនេះខ្លះ។ យើងអាចកាត់នំឲ្យទៅជា៨ដុំ ហើយយក៣ដុំ នេះនឹងទៅជា ៣/៨ ហើយយើងនឹងនៅមាន៥ដុំទៀត (៥/៨)។ ហើយក៏ដូចគ្នានឹង ផ្កា ទឹក ទឹកប៉ោម និងរបស់ផ្សេងៗ តាមតែអ្នកអាចគិតដល់។ យើងអាចចែកឲ្យទៅជាចំណែកស្មើៗគ្នា (ប៉ុន្មានចំណែកក៏ដោយ តាមតែយើងចង់បាន) ហើយយកចំណែកទាំងនោះ តាមតែយើងត្រូវការ។

សូមចាំថា យើងអាចកាត់នំលើសពីមួយឡើងទៅ ដូច្នេះ បើយើងមាន១០/៨ នេះមានន័យថា យើងមាននំទាំងមូល និងមាន២ដុំថែមទៀត។

## ទសភាគ

ភាពខុសគ្នារវាង ប្រភាគ និង ទសភាគ គឺចំនួនដុំដែលយើងកាត់នំរបស់យើង។ បើសិនជាចំនួនដុំជាពហុគុណនៃ១០ យើងមាន ទសភាគ។ ក្នុង ទសភាគ យើងអាចកាត់នំរបស់យើងបានតែ១០ដុំប៉ុណ្ណោះ ហើយបន្ទាប់មកកាត់ម្ដុំៗឲ្យទៅជា១០ចំណែកទៀត និងជាបន្តបន្ទាប់ទៀត។ ដូច្នេះយើងអាចមាន១០ដុំ ១០០ដុំ ១០០០ដុំ និងជាបន្តបន្ទាប់ទៀត។ ដោយសារយើងប្រើប្រព័ន្ធទសភាគជាការងាយស្រួលសម្រាប់យើង ក្នុងការពាក់ព័ន្ធជាមួយទសភាគ។

ប្រព័ន្ធទសភាគអនុញ្ញាតឲ្យយើងផ្លាស់ប្ដូរនំ៣/៨របស់យើងឲ្យទៅជាប្រភាគនៃទសភាគបានដោយងាយ៖

យើងគ្រាន់តែចែក ៣និង៨ ហើយយើងនឹងបានចម្លើយ ០,៣៧៥។ នេះមានន័យថា បើគេអនុញ្ញាតឲ្យយើងប្រើតែប្រព័ន្ធទសភាគដើម្បីកាត់នំរបស់យើង យើងត្រូវកាត់នំនេះឲ្យទៅជា ១០០០ដុំ ហើយបាន ៣៧៥ ដើម្បីឲ្យបាន ៣/៨ របស់យើង។ យើងក៏អាចផ្លាស់ប្តូរ ០,៣៧៥ ឲ្យទៅជាប្រភាគធម្មតា ដោយសម្រួលប្រភាគ ៣៧៥/១០០០។ (ដើម្បីសម្រួលប្រភាគ យើងអាចចែកលេខខាងលើ (ភាគយក) និងលេខខាងក្រោម (ភាគបែង) ដោយលេខដូចគ្នាបេះបិត។ សូមសាក ១២៥។)

## ភាគរយ

ភាគរយ (១%) គឺជាពាក្យពិសេសសម្រាប់ ១/១០០ ឬ ០,០១។ ដូចគ្នានេះដែរ ៥% ដូចគ្នានឹង ០,០៥ និង ១0% ដូចគ្នានឹង ០,១០ ឬគ្រាន់តែ ០,១។

## និទស្សន្តកម្ម/ការបង្កើនចំនួន និទស្សន្ត N

ដូចគ្នានឹងលេខបូក មានលេខដូចៗគ្នាច្រើនដងអាចជំនួសដោយលេខគុណ គុណលេខដូចគ្នាជាច្រើនដងអាចជំនួសដោយនិទស្សន្តកម្ម – បង្កើនលេខនេះ (គោល) ឲ្យទៅជាលេខអ្វីមួយ (ស្វ័យគុណ)។ ស្វ័យគុណ គឺជាចំនួនលេខដែលយើងត្រូវធ្វើលេខគុណ។ និយាយថាយើងមានសិស្ស៥នាក់ យកប្រអប់៥មក មួយប្រអប់មានសៀវភៅ៥ក្បាល យើងមាន ៥ x ៥ x ៥ ឬ $៥^{៣}$ (អានថា ៥ ស្វ័យគុណ ៣)។

ឧទាហរណ៍ដ៏ល្អសម្រាប់ស្វ័យគុណគឺការប្រាក់។ គិតថាយើងបណ្តាក់ទុន ដែលមានការប្រាក់ ៥%។ ក្នុងមួយឆ្នាំៗ បណ្តាក់ទុនរបស់យើងនឹងកើន ៥% ដូច្នេះក្នុងមួយឆ្នាំយើងនឹងមាន ១០៥% (ឬ ១,០៥) នៃចំនួនដែលយើងបានបណ្តាក់ទុន។ រយៈពេលពីរឆ្នាំយើងនឹងមាន ១,០៥ x ១,០៥ លើចំនួនដើម។ ចូរនិយាយថាយើងបណ្តាក់ទុន ១០០$ ក្នុងរយៈពេល២ឆ្នាំ យើងនឹងមាន ១០០ x ១,០៥២ ៣ឆ្នាំ ១០០ x ១,០៥៣ និងជាបន្តបន្ទាប់ទៀត។

## ឫស

យើងតែងតែមានប្រមាណវិធី នៅក្នុងគណិតវិទ្យា។ យើងមានលេខ បូក និងលេខដក លេខគុណ និងលេខចែក។ ដូចគ្នានេះដែរ យើងមាន ស្វ័យគុណ ឫស និងមេលេខជំរឿន។

បើសិនជាយើងគុណលេខនិងលេខខ្លះច្រើនដង ហើយយើងដឹងថាយើងគុណប៉ុន្មានដង និងដឹងលទ្ធផល យើងតែងតែអាចរកលេខនោះឃើញ។ អ្វីដែលយើងត្រូវការគឺប្រើឫស N ដែល N ជាចំនួនដែលយើងគុណ។

ឧបមាថា អ្នកឈ្នះឆ្នោតចំនួន ២៥០$។ អ្នកគិតដល់ការបណ្តាក់ទុនយកការប្រាក់រហូតដល់អ្នកចូលនិវត្តន៍ ហើយបន្ទាប់មក ទៅដើរលេងឲ្យសប្បាយ។ អ្នកជឿថា អ្នកត្រូវការប្រាក់ចំនួន១០០០$ ដើម្បីបង់ថ្លៃដើរលេងរបស់អ្នក។ នេះមានន័យថា ក្នុងកំឡុងពេល២០ឆ្នាំ ប្រាក់ចំនួន២៥០$ របស់អ្នក ត្រូវកើនមួយជាបួន (១០០០$/២៥០$)។ តើយើងត្រូវធ្វើដូចម្តេចទើបដឹងថា ការប្រាក់ប៉ុន្មាននឹងធ្វើឲ្យយើងអាចកើនមួយជាបួន ក្នុងរយៈពេល២០ឆ្នាំ? ងាយស្រួលមែនទែន៖ ម៉ាស៊ីនគិតលេខរបស់កូនអ្នកអាចរកមើលឲ្យដឹងពីចំនួនការប្រាក់។ ចុច 20 root ($^{x}\sqrt{}$) និង 4 ដើម្បីរក $^{20}\sqrt{}$ (អានថា ម្ភៃទៅនឹងឫសបួន)។ ចម្លើយគឺប្រហែលជា ១,០៧។ យើងត្រូវការយ៉ាងហោចណាស់ឲ្យបានចំណេញ ៧%លើប្រាក់បណ្តាក់ទុន របស់យើង! របៀបសរសេរផ្សេងទៀត $^{20}\sqrt{4}$ គឺ $4^{20}$ ឬ $4^{0.05}$។ នេះមានន័យថា អ្នកអាចប្រើនិទស្សន្តកម្ម (សញ្ញា ^ នៅលើម៉ាស៊ីនគិតលេខ) ដើម្បីគិតលេខនេះ។

## មេលេខជំរឿន ( LOGARITHMS )

មេលេខជំរឿនគឺជាប្រមាណវិធីទាំងបួនផ្សេងទៀត សម្រាប់និទស្សន្តកម្ម។ ពេលនេះយើងត្រូវរកនិទស្សន្តកម្ម ឬចំនួនប៉ុន្មានដងដែលត្រូវគុណ (គោល) ដើម្បីរកចម្លើយដែលចង់បាន។ ឧបមាថា យើងនៅតែមានប្រាក់ ២៥០$ ហើយយើងចង់ធ្វើឲ្យកើនដល់ ១០០០$ ជាច្រើនឆ្នាំទៅមុខ ប៉ុន្តែយើងអាចចំណេញតែ៥% តែប៉ុណ្ណោះ សម្រាប់បណ្តាក់ទុនដែលមិនខាតបង់។ តើយើងត្រូវចំណាយពេលប៉ុន្មានឆ្នាំទើបសម្រេចតាមគោលបំណងរបស់យើង? ជាថ្មីម្តងទៀត យើងចង់ឲ្យកើន មួយជាបួន (១០០០$/២៥០$)។ ចម្លើយគឺ log1.05(4) ឬ 28.4 ឆ្នាំ។ ម៉ាស៊ីនគិតលេខភាគច្រើនមានតែ natural logarithms ឬ logarithms ដែលមានគោល ១០។ ដើម្បីដោះស្រាយសំណួររបស់យើង ៗអាចជំនួស log1.05 (4) ដោយ log10 (4)/ log10 (1.05)។ )

# ការវាយតម្លៃ ការសរសេរ

ការវាយតម្លៃការសរសេរ មានម្ភៃសំណួរ ដែលមានចម្លើយសម្រាប់ជ្រើសរើស កែសម្រួល និងពិនិត្យផ្ទៀងផ្ទាត់ និងវិញ្ញាសាបី សម្រាប់សរសេរ។

ការសរសេរ ចំពោះចម្លើយដែលតម្រូវឲ្យមានការសរសេរ ត្រូវបានគេវាយតម្លៃតាមទស្សនៈនៃអត្ថបទ ដែលមានអត្ថន័យ ការផ្ចង់ទៅលើបញ្ហា ការអភិវឌ្ឍន៍នៃគំនិត របៀបរៀបចំ និងបែបបទនៃការសរសេរ។

របៀបឲ្យពិន្ទុ រួមបញ្ចូលគោលការណ៍ណែនាំ ក្បួនច្បាប់នៃការឲ្យពិន្ទុ ដែលគិតអំពីការប្រើរបស់សិស្ស នៃក្បួនសរសេរ (ឃ្លា ព័ត៌មាន វេយ្យាករណ៍ ការប្រើពាក្យ អក្ខរាវិរុទ្ធ និងវណ្ណយុត្ត)។ តែងសេចក្តី និងក្បួនសរសេរ ត្រូវបានគេឲ្យពិន្ទុតាមកម្រិត៤ពន្ទុ ដាច់ដោយឡែកពីគ្នា ដើម្បីវាយតម្លៃចំណេះដឹងរបស់អ្នកសរសេរ។

**លោកអ្នកអាចមើល ឧទាហរណ៍ សំណួរ និង ចម្លើយដែលត្រូវ សម្រាប់ថ្នាក់នីមួយៗ នៅក្នុង ឧទាហរណ៍ សំណួរ និង ការឲ្យពិន្ទុ នៃការសរសេរ។** សូមមើលនៅក្នុង «Test Preparation Web Resources» ខាងលើ សម្រាប់ការបង្ហាញមួយដំណាក់ម្តងៗ។

## គោលការណ៍ណែនាំ ពីការឲ្យពិន្ទុ នៃការវាយតម្លៃ ការសរសេរ

| | ការផ្ចង់ទៅលើបញ្ហា | ខ្លឹមសារ | របៀបរៀបចំ | បែបបទនៃការសរសេរ | ក្បួនសរសេរ |
|---|---|---|---|---|---|
| 4 | ការផ្ចង់ទៅលើគំនិតតែមួយ ដោយយល់ពីកិច្ចការ (វិធី) របស់ប្រធានបទ។ | ការបង្ហាញពីគំនិត តាមរយៈ ការពិត ឧទាហរណ៍ រឿងខ្លីៗ ការលម្អិត មតិស្ថិតិ ហេតុផល និង/ឬ ការពន្យល់ | ការអភិវឌ្ឍន៍ និងការគាំទ្រនៅក្នុង ឬ ពីល្បះខ័ណ្ឌមួយ ទៅល្បះខ័ណ្ឌមួយ ដោយមានរួមទាំង សេចក្តីផ្តើម និង សេចក្តីបញ្ចប់ | ការជ្រើសរើស ការប្រើ និងការរៀបពាក្យ និងការរៀបឃ្លា ដែលបង្ហាញពីរបៀបសរសេរ | ការប្រើ វេយ្យាករណ៍ វណ្ណយុត្ត អក្ខរាវិរុទ្ធ ការប្រើពាក្យ និងការរៀបឃ្លា |
| | ច្បាស់ ប្លែកក្នុងការផ្ចង់ទៅលើគំនិត តែមួយ ដោយយល់ពីកិច្ចការ (វិធី) របស់ប្រធានបទ។ | ត្រឹមត្រូវ ច្បាស់លាស់ និង/ឬ ពន្យល់ខ្លឹមសារ ដែលបង្ហាញ ការអភិវឌ្ឍន៍ ដ៏ប៉ិនប្រសប់ និងគំនិតឈ្លាសវៃ | ឈ្លាសវៃ ក្នុងការរៀបចំខ្លឹមសារ មាន ភស្តុតាង និង/ឬ ប៉ិនប្រសប់ក្នុងការផ្លាស់ប្តូរ | ច្បាស់លាស់ ការពន្យល់ឲ្យឧទាហរណ៍ ដោយប្រើពាក្យ និងរបៀបរៀបឃ្លា ជាច្រើនប្រភេទ ដើម្បីរក្សារបៀបសរសេររបស់អ្នកនិពន្ធ និងមានលក្ខណៈសមរម្យសម្រាប់អ្នកអាន | ភស្តុតាង ពីការរក្សាបាននូវ ការប្រើ វេយ្យាករណ៍ វណ្ណយុត្ត អក្ខរាវិរុទ្ធ ការប្រើពាក្យ និងការរៀបឃ្លា |
| 3 | បង្ហាញគំនិតដែលផ្ចង់ទៅលើប្រធានបទតែមួយ ដោយយល់ពី កិច្ចការ (វិធី) របស់ប្រធានបទ។ | មានខ្លឹមសារពេញលេញជាមួយ ការលម្អិត ឬការពន្យល់ គ្រប់គ្រាន់ | មានគោលបំណងក្នុងការរៀបចំ ខ្លឹមសារ ដែលគាំទ្រដល់លំដាប់ សមហេតុផល ដែលមានភស្តុតាងនៃការផ្លាស់ប្តូរ | ការប្រើពាក្យ និងរបៀបរៀបឃ្លា ធម្មតា ជាច្រើនប្រភេទ ដែលអាច ឬមិនអាចរក្សារបៀបសរសេររបស់អ្នកនិពន្ធ ដែលមានលក្ខណៈសមរម្យសម្រាប់អ្នកអាន | រក្សាបាននូវ ការប្រើ វេយ្យាករណ៍ វណ្ណយុត្ត អក្ខរាវិរុទ្ធ ការប្រើពាក្យ និងការរៀបឃ្លា |
| 2 | អត់បង្ហាញពីគំនិត ប៉ុន្តែមាន ភស្តុតាងនៃប្រធានបទជាក់លាក់ | មានខ្លឹមសារតិចតួច ជាមួយ ការលម្អិត ឬការពន្យល់ គ្រប់គ្រាន់ | ច្រឡូកច្រឡំ ឬ អត់មានស្ថិរភាព ក្នុងការរៀបចំអត្ថន័យ មាន ឬមិនមានបំណងក្នុងការផ្លាស់ប្តូរ | ការប្រើពាក្យ និង របៀបរៀបឃ្លា មានកម្រិត ដែលមិនអាចឲ្យគេយល់ពីរបៀបសរសេរ | រក្សាបានខ្លះនូវ ការប្រើ វេយ្យាករណ៍ វណ្ណយុត្ត អក្ខរាវិរុទ្ធ ការប្រើពាក្យ និងការរៀបឃ្លា |

| | | | | | |
|---|---|---|---|---|---|
| 1 | មានភស្តុតាង នៃ ប្រធានបទ តិចតួច | មានខ្លឹមសារ ស្រាល និង/ឬ តិចតួច | រក្សាការរៀបចំ ខ្លឹមសារ បានតិចតួច | ការប្រើពាក្យ និង របៀប រៀបឃ្លា បានតិតតួច | រក្សាបានតិចតួចនូវ ការប្រើ វេយ្យាករណ៍ វណ្ណយុត្ត អក្ខរាវិរុទ្ធ ការប្រើពាក្យ និងការ រៀបឃ្លា |
| 0 | មិនអាចឲ្យពិន្ទុបាន (Non-Scorable)<br>✓ អានមិនដាច់ ឧ. រួមទាំង ពាក្យជាច្រើនមិនអាចអានបាន មិនអាចដឹងពី អត្ថន័យគំនិតដែលបានសរសេរ<br>✓ មានទាក់ទងគ្នា ឧ. ពាក្យអាចអានដាច់ ប៉ុន្តែវាក្យសម្ព័ន្ធ (ការរៀបពាក្យ) មិនច្បាស់លាស់ ដែលធ្វើឲ្យចម្លើយគ្មានអត្ថន័យ<br>✓ គ្មានលក្ខណៈគ្រប់គ្រាន់ ឧ. គ្មានលក្ខណៈគ្រប់គ្រាន់ ដើម្បីវាយតម្លៃគ្រប់ វិស័យទាំងអស់<br>✓ ក្រដាសស | | | ចាកប្រធាន (Off-Prompt)<br>អាចអានបាន ក៏ប៉ុន្តែមិនឆ្លើយតបទៅនឹងប្រ ធានបទ | |

## ការវាយតម្លៃ ចំណេះវិទ្យាសាស្ត្រ

ការវាយតម្លៃចំណេះវិទ្យាសាស្ត្រ គឺទៅលើសេចក្តីរាយ ការណ៍បួនផ្នែកសំខាន់ៗ៖

- វិទ្យាសាស្ត្រធម្មជាតិ
- ជីវសាស្ត្រវិទ្យា
- រូបវិទ្យា និង
- វិទ្យាសាស្ត្រអំពី ផែនដី និងលំហ

ចំនួននៃសំណួរទាំងអស់គឺផ្តោតទៅលើផ្នែកនីមួយៗ ហើយ មានលក្ខណៈខុសៗគ្នាទៅតាមកម្រិតថ្នាក់។ ផ្នែកនីមួយៗ មានគំរូនៃការវាយតម្លៃ(Assessment Anchors) និង អត្ថន័យ ដែលមានលក្ខណៈគ្រប់គ្រាន់ (Eligible Content) ដែលបាន ផ្តល់ឲ្យតាមរយៈវ៉ិបសៃរបស់ក្រសួងអប់រំ នៃរដ្ឋផិនស៊ីលវេញ៉ា។

- មើលក្នុងវ៉ិបសៃ http://www.education.state.pa.us
- នៅក្នុងបញ្ជីខាងឆ្វេងដៃ សូមចុច «Programs»
- ចុចត្រង់ «Programs O-R»
- ចុចត្រង់ «Pennsylvania System of School Assessment (PSSA)»
- ចុចត្រង់ «Assessment Anchors»

ថ្នាក់ទី៨ និងទី១១ ក្រៅពី សំណួរដែលសរសេរតាមគំនិត របស់ខ្លួន និងសំណួរដែលមានចម្លើយសម្រាប់ជ្រើសរើស ក៏មាន ស្ថានភាពរួមនៃវិទ្យាសាស្ត្រ សម្រាប់ការវាយតម្លៃ នៃវិទ្យាសាស្ត្រ ផងដែរ។

ស្ថានភាពរួមនៃវិទ្យាសាស្ត្រ មាន អត្ថបទ ក្រាហ្វិច តាង រង្វាស់ និង/ឬតារាង ហើយគេនិងយកអ្វីទាំងនេះ ទៅ



ពន្យល់ពីលទ្ធផល នៃកិច្ចការ ឬពិសោធន៍ ឬពីការស្រាវ ជ្រាវដែលប្រហាក់ប្រហែលគ្នានេះដែរ។ សិស្សនឹងយក ព័ត៌មានដែលរកឃើញនៅក្នុងស្ថានភាពទូទៅ ដើម្បីផ្តល់ ចម្លើយនៅក្នុង ចម្លើយសម្រាប់ជ្រើសរើស និងចម្លើយ តាមគំនិតរបស់ខ្លួន។

នៅក្នុងចំណេះវិទ្យាសាស្ត្រ ពិន្ទុទាំងអស់គឺផ្អែកទៅលើ អត្ថន័យ តែប៉ុណ្ណោះ។ អក្ខរាវិរុទ្ធ និងការប្រើវណ្ណយុត្ត មិន រាប់បញ្ចូលនៅក្នុងវិធីឲ្យពិន្ទុនោះទេ។

**លោកអ្នកអាចមើល ឧទាហរណ៍ សំណួរ និង ចម្លើយ ដែលត្រូវ សម្រាប់ថ្នាក់នីមួយៗ នៅក្នុង ឧទាហរណ៍ សំណួរ និង ការឲ្យពិន្ទុ នៃចំណេះវិទ្យាសាស្ត្រ។** សូមមើល នៅក្នុង «Test Preparation Web Resources» ខាងលើ សម្រាប់ការបង្ហាញមួយដំណាក់ម្តងៗ។

## ព័ត៌មាននៅក្នុងវិបសៃ សម្រាប់ការត្រៀមប្រឡង

ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា
គំរូមុខវិជ្ជានៅក្នុងការប្រឡងនិងការឲ្យពិន្ទុ

- ការរៀនធ្វើ គណិតវិទ្យា ការអាន វិទ្យាសាស្ត្រ និងការសរសេរ
- គំរូសម្រាប់សំណួរដែលមានចម្លើយសម្រាប់ជ្រើសរើស
- គំរូសម្រាប់សំណួរដែលឆ្លើយតាមគំនិតរបស់ខ្លួន
- សន្ទានុក្រម

- ▶ មើលវិបសៃ http://www.education.state.pa.us
- ▶ ក្នុងបញ្ជីនៅខាងឆ្វេងដៃ រើសយកពាក្យ "Programs"
- ▶ ចុចត្រង់ពាក្យ "Programs O–R"
- ▶ ចុចត្រង់ពាក្យ "Pennsylvania System of School Assessment (PSSA)"
- ▶ រើសយក "Items and Scoring Samples"

នេះជាទំព័រវិបសៃដែលរៀបរាប់ដោយសង្ខេបអំពី "គំរូមុខវិជ្ជានៅក្នុងការប្រឡងនិងការឲ្យពិន្ទុ"។

នេះគឺជារូបភាពទំព័រវិបសៃ នៃ «ឧទាហរណ៍ សំណួរ និងការឲ្យពិន្ទុ»




ត្រង់នេះលោកអ្នកអាចជ្រើសរើសមុខវិទ្យា និងថ្នាក់ដែលលោកអ្នកចង់ដឹង និងអាចចម្លងចេញជាឯកសារ pdf។ នៅក្នុងឯកសារនីមួយៗមាន សំណួរ ឧទាហរណ៍ និងការពន្យល់។

**A.1.3.1**

**2.** Leonard started writing factors of the number 9 below, but did not finish.

1, 3, __

Which factor of 9 is missing?

A 4 — *added 1 and 3*

B 5 — *saw numbers were increasing by 2 and added 2 to 3*

C 6 — *doubled the 3*

D 9 *

| A | B | C | D |
|---|---|---|---|
| 4% | 26% | 19% | 51% |

**A.1.3.2**

**3.** Which shows only multiples of 3?

A 43, 53, 63 — *all end in 3, only 63 is a multiple of 3*

B 49, 56, 63 — *all numbers end in a number divisible by 3*

C 43, 46, 49 — *goes up by 3, first number ends in 3*

D 60, 63, 66 *

| A | B | C | D |
|---|---|---|---|
| 14% | 7% | 21% | 58% |

**A.2.1.1**

**4.** A baker uses 2 cups of wheat flour and 4 cups of white flour to bake a loaf of bread. How much flour in all will the baker use to bake 5 loaves of bread?

A 10 cups — *$2 \times 5$*

B 20 cups — *$4 \times 5$*

C 30 cups *

D 40 cups — *$2 \times 4 \times 5$*

| A | B | C | D |
|---|---|---|---|
| 15% | 15% | 54% | 16% |

**A.2.1.2**

**5.** Tim bought 2 paintbrushes that each cost $2.55. He also bought 1 bucket that cost $1.60. How much did Tim pay in all?

A $3.50 — *$2.55 \times 2 - 1.60$*

B $4.15 — *$2.55 + 1.60$*

C $6.15 — *$2 + 2.55 + 1.60$*

D $6.70 *

| A | B | C | D |
|---|---|---|---|
| 2% | 36% | 4% | 57% |

## ព័ត៌មាននៅក្នុងវិបសៃ (ត)

### FamilyNet (បណ្ដាញមាតាបិតា)

- អាចមើលទិន្នន័យថ្មីៗនៃការរីកចម្រើន វត្តមានអវត្តមាន ចំណាត់ថ្នាក់ ពិន្ទុនៃការប្រឡងតាមខ្នាតគំរូ របស់កូនលោកអ្នក
- ឯកសារនៃការបង្ហាត់បង្រៀន–សៀវភៅមេរៀន ការជួយបង្រៀនតាមអិនធ័រនែត និង អ្វីៗផ្សេងទៀត

▸ មើលក្នុង www.philasd.org

▸ នៅលើប្រអប់ពណ៌បៃតង សម្រាប់មាតាបិតាចុច បណ្ដាញតភ្ជាប់ទីពីរ– "FamilyNet"

▸ បើសិនជាលោកអ្នកគ្មានឈ្មោះ (account) FamilyNet ប្រើទេនោះ លោកអ្នកអាចបង្កើតឈ្មោះមួយដោយងាយស្រួលបំផុត ដោយចុចត្រង់ "Register for an Account"។

## ព័ត៌មានផ្សេងទៀត

### BBC Learning

www.bbc.co.uk/schools/students

- វីដេអូ សកម្មភាពផ្សេងៗ និងព័ត៌មានអំពីមុខវិជ្ជារៀននៅសាលា ជាច្រើនទៀត

### Everyday Math – Parent Connection

www.wrightgroup.com/parent_connection/

- មាតិកា ទម្រង់ និង ក្បួនដោះស្រាយបញ្ហា

▸ ចុចត្រង់ "Tips and Activities"

### First in Math

www.firstinmath.com

- រៀនធ្វើលំហាត់គណិតវិទ្យា តាមអិនធ័រនែត

▸ កូនរបស់លោកអ្នកអាចយក ពាក្យសម្ងាត់ ពីគ្រូ

### ImagineIt

www.imagineitreading.com

- ព័ត៌មានពីការអាន សម្រាប់ថ្នាក់មត្តេយ្យ-ទី៦

### Math Forum @ Drexel

http://mathforum.org

- ជួយផ្ដល់ជំនិត
- សន្ទានុក្រម
- Ask Dr. Math

### Mifflin County District Curriculum Links

http://www.mcsdk12.org/curr/standardized_test_preparation.htm

- ហាត់ធ្វើវិញ្ញាសាសម្រាប់ប្រឡង

### My TestBook.com

www.mytestbook.com

- រៀនឆ្លើយសំណួរ គណិតវិទ្យា ការអាន និងចំណេះវិទ្យាសាស្ត្រ

### SpellingCity

www.spellingcity.com

- ព័ត៌មានអំពី ការប្រកបអក្សរ និងវាក្យស័ព្ទ

### Starfall

www.starfall.com

- រៀនអាន – ថ្នាក់ទាបៗ

### www.abclearningtime.com

www.abclearningtime.com

- អក្សរសាស្ត្រថ្នាក់ទាបៗ៖ ល្បែង ប្រាស្នា និង លំហាត់ដែលផ្ដោតទៅលើការរៀនសរសេរ

### StudyStack

www.studystack.com

- ល្បែងលេងសម្រាប់ រៀនពាក្យ

(crossward puzzles, flash cards, scrabble and more)

▸ នៅក្នុងប្រអប់រាវរក លើទំព័រដើម្បី សរសេរពាក្យ "PSSA" ហើយជ្រើសថ្នាក់ និងមុខវិទ្យា ពីក្នុងបញ្ជី ដើម្បីហាត់រៀន

### University of Missouri eThemes

http://ethemes.missouri.edu

- ព័ត៌មានសម្រាប់ គ្រប់មុខវិទ្យាទាំងអស់

### TLSBooks

www.tlsbooks.com

- ទំព័រលំហាត់ គ្រប់មុខវិទ្យាសិក្សាទាំងអស់ សម្រាប់សិស្សថ្នាក់បឋមសិក្សា (គេបានផ្ដល់ឲ្យនូវគន្លិះនៃចម្លើយទែងអស់)។

## ព័ត៌មាន និងសិក្ខាសាលា សម្រាប់មាតាបិតា

សាលារបស់ក្រសួងជាច្រើន បានរៀបចំសិក្ខាសាលាប្រចាំខែ ដើម្បីជួយដល់មាតាបិតា ដោះស្រាយនូវបញ្ហាជាច្រើនដែលទាក់ទងនឹងសាលា មានរួមទាំងការស្វែងយល់អំពីកម្មវិធីសិក្សាសំខាន់ៗ និងការត្រៀមខ្លួនសម្រាប់ប្រឡង PSSA។ សូមទូរស័ព្ទទៅសាលារបស់លោកអ្នកដើម្បីសួរនាំព័ត៌មានអំពីសិក្ខាសាលាក៏ដូចជាកម្មវិធីសម្រាប់មាតាបិតា និងឱកាសដែលមាតាបិតាអាចចូលរួម ដែលបានផ្ដល់ជូនដោយសាលារបស់លោកអ្នក។

## ជួយកែលម្អសាលារបស់លោកអ្នក – ចូលធ្វើជាសមាជិក នៃគណកម្មការក្រុមប្រឹក្សាសាលា!

ក្រុមប្រឹក្សាសាលា

# SACs

*គិតដល់ការសហការគ្នា រវាងសាលា និង មាតាបិតា ដើម្បីជោគជ័យរបស់សិស្ស*

ក្រុមប្រឹក្សាសាលា (ឬ SACs) គឺជាផ្នែកនៃទម្រង់ដឹកនាំទូទៅ នៅសាលានីមួយៗ។ ផ្តល់វេទិកាសម្រាប់ការពិភាក្សាដោយចំហ និងការដោះស្រាយបញ្ហា ដែលទាក់ទងនឹងជោគជ័យរបស់សិស្ស ក្រុមប្រឹក្សាសាលាផ្តល់ឲ្យក្រុមអ្នកសំខាន់ៗទាំងអស់ (អភិបាលសាលា មាតាបិតា សិស្សានុសិស្ស បុគ្គលិក និងសហគមន៍ទាំងមូល)នូវសម្លេងពិត ពីការសម្រេចចិត្តនៅសាលា និងអំណាចដើម្បីឲ្យមានអានុភាពលើកិច្ចការទាំងអស់របស់សាលា។ ក្រុមប្រឹក្សាសាលា ជួយធ្វើឲ្យមានការសហការ និងការយល់ដឹង និងបង្កើតការគាំទ្រ សម្រាប់គោលបំណងទូទៅ ព្រមទាំង កម្មវិធីនីមួយៗ ច្បាប់ និង ការផ្តើមគំនិតថ្មីៗ របស់សាលា។

ក្រុមប្រឹក្សាសាលាមាន អ្នកតំណាងពីក្រុមអ្នកសំខាន់ៗផ្សេងៗ នៅសាលា ដែលបានបោះឆ្នោតជ្រើសរើសដោយអ្នកស្គាល់គ្នា ការទទួលខុសត្រូវសំខាន់បំផុតរបស់ពួកគេ គឺ ការសហការជាមួយនាយកសាលា ចំពោះកិច្ចការដែលប៉ះពាល់ដល់ជោគជ័យរបស់សិស្ស និងការកែលម្អសាលា។ មុខនាទីដ៏សំខាន់របស់ពួកគេគឺ ចូលរួមក្នុងវិធីសម្រេចចិត្ត គឺធ្វើយ៉ាងណាឲ្យសេចក្តីត្រូវការរបស់សិស្សទាំងអស់ ត្រូវបានគេលើកឡើងនៅក្នុង ផែនការសម្រាប់អនុវត្ត និងថវិកា របស់សាលា — គឺជាឯកសារសំខាន់ៗពីរដែលរៀបចំសម្រាប់គម្រោងសិក្សាទូទៅ សម្រាប់សាលា។

ការសិក្សាស្រាវជ្រាវថ្មីៗបានឲ្យយោបល់ថា ពេលណាមានការអនុវត្តន៍ត្រឹមត្រូវ គម្រោងការណ៍ដែលមានការពិគ្រោះគ្នា នាំឲ្យមានការកែលម្អវប្បធម៌របស់សាលា និងបង្កើតឲ្យមានសហគមន៍សិក្សាដ៏រឹងមាំ។ ជាបន្ថែមទៀត ការសម្រេចចិត្តដែលមានប្រសិទ្ធិភាព អាចគាំទ្រដល់ ការអនុវត្តន៍នៅក្នុងថ្នាក់រៀន និងការសិក្សារបស់សិស្ស។

ការស្រាវជ្រាវដ៏ទូលំទូលាយអំពី ក្រុមប្រឹក្សាសាលានៅរដ្ឋ ឈីខាហ្គោ បានបង្ហាញឲ្យឃើញថា ក្រុមប្រឹក្សាសាលាមានឥទ្ធិពលល្អដល់ជោគជ័យរបស់សិស្ស។ មានទំនាក់ទំនងយ៉ាងខ្លាំង រវាងសាលាដែលមានក្រុមប្រឹក្សាសាលាដែលមានប្រសិទ្ធិភាព និងសាលាដែលមានការកើនឡើងខ្ពស់ចំពោះពិន្ទុនៃការប្រឡង។ ជាបន្ថែមទៀត ការស្រាវជ្រាវបានឲ្យដឹងថា ក្រុមប្រឹក្សាសាលា បានបង្កើនការទទួលខុសត្រូវ និងជំរុញមាតាបិតាទាំងអស់ឲ្យចូលរួមកាន់តែច្រើន នៅក្នុងសហគមន៍របស់គាត់។

**ដើម្បីជ្រាបបន្ថែមទៀតអំពី SACs យកលិខិតដាក់ពាក្យសុំ ឬស្នើសុំជំនួយក្នុងការរៀបចំបង្កើតក្រុមប្រឹក្សាសាលា នៅសាលារបស់លោកអ្នក សូមមើលវិបសៃរបស់យើងខ្ញុំ www.philasd.org/sac អ៊ីមែល sac@philasd.org ឬទូរស័ព្ទទៅ ២១៥-៤០០-៤១៨០ (រើសយកលេខ ១)។**

## ត្រៀមខ្លួនសម្រាប់

# PSSA

## កូនសៀវភៅ អំពី ជ័យជំនះរបស់សិស្ស សម្រាប់មាតាបិតា

### ផ្តើមគំនិត និង មើលខុសត្រូវ

**Karren Dunkley**
នាយិការង
*ការិយាល័យទំនាក់ទំនងជាមួយ មាតាបិតា ក្រុមគ្រួសារ សហគមន៍ និងការសហការជាមួយក្រុមសាសនា*

### រៀបរៀង និង ចាត់ចែងផែនការ

**Julia Manokhina**
អ្នកចាត់ចែងកម្មវិធី
*ការិយាល័យទំនាក់ទំនងជាមួយ មាតាបិតា ក្រុមគ្រួសារ សហគមន៍ និងការសហការជាមួយក្រុមសាសនា*

### ការថ្លែងអំណរគុណ ពិសេស

**Rasheeda Boatright**
គ្រូនៅសាលាបឋមសិក្សា
Samuel B. Huey

*សម្រាប់ជំនួយក្នុងការ ចងក្រង និងកែសម្រួល កូនសៀវភៅនេះ*

**Melissa Chizmadia,**
*ភ្នាក់ងារផ្តល់ជំនួយផ្នែកបង្ហាត់បង្រៀន ផ្នែកសិក្សាធិការប្រចាំតំបន់ ៩*

សម្រាប់ការចែកចាយឯកសារ បង្ហាត់បង្រៀន និងព័ត៌មាន ប្រើក្នុងកូនសៀវភៅនេះ

គិតដល់ឆ្នាំ ២០១៤

PARENT UNIVERSITY

មាតាបិតា គឺជាដៃគូរបស់យើង

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដាលហ្វា៉

# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា៉

សាកលវិទ្យាល័យមាតាបិតារបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា៉ គឺស្របតាមផែនការនៃការគិតដល់ ឆ្នាំ២០១៩។ ការស្រាវជ្រាវបានបង្ហាញឲ្យឃើញថា ពេលណាក្រុមគ្រួសារ ចូលរួមក្នុងការសិក្សា ពួកគេនឹងចូលរួមយ៉ាងសកម្មក្នុងការស្វែងរកវិធីសាស្ត្រអប់រំ។

សាកលវិទ្យាល័យមាតាបិតា នឹងទាក់ទាញមាតាបិតាឲ្យចូលរួមក្នុងការចាប់ផ្តើមគំនិតថ្មី និង មានអត្ថន័យសម្រាប់ការសិក្សា។ ការបង្កើនឲ្យមានការចូលរួមពី មាតាបិតាទាំងនេះ នឹងនាំឲ្យមានជោគជ័យដល់ការសិក្សា និងទំនាក់ទំនងក្នុងសង្គម របស់ក្មេង។ តាមការផ្តល់ជូនសិក្ខាសាលា និងថ្នាក់រៀនផ្សេងៗ សាកលវិទ្យាល័យមាតាបិតា នឹងបង្កើតឲ្យមានសហគមន៍សិក្សាដ៏រឹងមាំ ដើម្បីបង្កើនជោគជ័យរបស់សិស្ស។ តាមការសហការជាមួយផ្នែកផ្សេងៗ ដែលនៅក្នុងក្រសួងអប់រំ វិទ្យាស្ថានសិក្សា និងអង្គការ និងក្រុមសាសនា នៅក្នុងសហគមន៍ សាកលវិទ្យាល័យមាតាបិតា នឹងជួយផ្គត់ផ្គង់ដល់ក្រុមគ្រួសារនូវទេពកោសល្យ ចំណេះដឹង និង ជំនួយថែមទៀត។

**គោលបំណងរបស់សាកលវិទ្យាល័យមាតាបិតាគឺ ដើម្បី៖**

- ផ្តល់ឲ្យមាតាបិតានូវ ចំណេះដឹងដែលមានអំណះអំណាង ការប៉ិនប្រសប់ និង ជំនួយ ដើម្បីគាំទ្រដល់ការអប់រំរបស់កូនគាត់ និង បង្កើនជោគជ័យរបស់សិស្ស។
- គាំទ្រដល់មាតាបិតាក្នុងការរិះរកវិធីអប់រំ ដើម្បីធ្វើឲ្យសង្គមកាន់តែល្អឡើង
- ជួយឲ្យមាតាបិតាមានសិទ្ធិអំណាច និង មានការចូលរួម តាមរយៈការអប់រំ ដើម្បី គាំទ្រ និង ពង្រឹង ក្រុមគ្រួសារ។
- កែលម្អការសហការរវាង សាលា និង ក្រុមគ្រួសារ។
- បង្កើនចំនួនមាតាបិតា ដែលយល់ស្របថា សាលារបស់កូនគាត់បានធ្វើឲ្យមាតាបិតាចូលរួមដោយប្រសិទ្ធិភាព និង ឲ្យតម្លៃដល់មតិយោបល់របស់ពួកគាត់។
- បង្កើនចំនួនក្រុមគ្រួសារ ដែលយល់ថា ពួកគាត់អាចទទួលកម្មវិធីដែលមានគុណភាពល្អ របស់សាលា។
- បង្កើនចំនួនក្រុមគ្រួសារ ដែលឲ្យពិន្ទុសាលារបស់ពួកគាត់ A ឬ B នៅលើលិខិតស្ទង់មតិប្រចាំឆ្នាំរបស់ក្រសួងអប់រំ។
- ផ្តល់ ឱកាស និង ការគាំទ្រ ដល់មាតាបិតា ដើម្បីឲ្យពួកគាត់បានសម្រេចនូវគោលបំណងក្នុងការសិក្សា និង ក្រៅពីការសិក្សា។
- ធ្វើឲ្យមាន បណ្តាញ និង ទំនាក់ទំទង ក្នុងបណ្តា គ្រួសារ និងសាលា។

**សូមមើលវិបសៃ www.philasd-parentuniversity.org ឬទូរស័ព្ទមកលេខ ២១៥-៤០០-៨១៨០ ដើម្បីស្វែងយល់បន្ថែម អំពីថ្នាក់ដែលយើងខ្ញុំផ្តល់ជូនសម្រាប់ជួយដល់មាតាបិតា**


មាតាបិតា គឺជាដៃគូរបស់យើង

**គណកម្មាធិការកែទម្រង់សាលារៀន**

**ប្រធាន**
Robert L. Archie

**សមាជិក៖**
Feather Houstoun
Lorene Cary
Joseph A. Dworetzky
Wendell E. Pritchett

**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា៉**

**អគ្គនាយកក្រសួងអប់រំស្តីទី និងអគ្គនាយកផ្នែកកែប្រែស្ថានភាព**
Tom Knudsen

**នាយិកា ផ្នែកសិក្សាធិការ**
Penny Nixon

**នាយិការង**

**ការិយាល័យទំនាក់ទំនងជាមួយមាតាបិតា ក្រុមគ្រួសារ សហគមន៍ និងការសហការជាមួយក្រុមសាសនា**
Karren N. Dunkley